# ការសំភាសន៍ជាលើកទី២របស់លោកពូ អោម វិបុល

កះ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខះ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ អោម វិបុល

## ការសង្ខេបរបស់លោកពូ អោម វិបុល

នៅក្នុងការសំភាសន៍ជាលើកទី២នេះ
លោកពូបានប្រាប់ពីជីវិតគាត់ដោយសារតែអត់មានអ្វីហូបគាត់បានរត់ទៅចូលធ្វើជាកងទ័ពខ្មែរក្រហម ហើយមានពេលមួយគាត់ក៏បានធ្វើទ័ពអោយអ្នកម៉ូលីណាកាដែរ ហើយពួកវៀតណាមបានចាប់បានហើយបាញ់ចោលពួកដែលទៅជាមួយពូនោះទៅ៣០០នាក់សល់តែ៤០មកវិញតែប៉ុណ្ណោះ
ហើយគេចាប់លោកពូដាក់គុកហើយពេលមុជទឹកពេលហ្នឹងនៅពេលសម័យបែកហើយ
ហើយមានប្រជាជនធ្វើដំនើរទៅស្រុកជាច្រើនពាន់នាក់ដើរតាមផ្លូវ
ហើយពូលួចរត់ចូលទៅក្នុងចំនោមហ្នឹងក៏គាត់បានរួចខ្លួន។ នៅក្នុងសម័យសង្គ្រាមប៉ុល ពត គឺបងប្អូនម្តាយ ត្រូវបានស្លាប់ហើមដោយអាអត់បាយ ហើយគាត់មិនបានដឹងទេទាល់តែបែកហើយទើបដើររកបងប្អូនគេប្រាប់ថាគ្រួសារហ្នឹងស្លាប់អស់យូរណាស់ហើយ
ពូដើរសាត់ព្រាត់តែម្នាក់ឯង
តែពេលមកដល់ស្រុកវិញក៏បានជួបនឹងសាច់ញាតិហើយម្នាក់ៗគេយំអានិតគាត់គ្រប់គ្នា ។ ជីវិតរបស់លោកពូគឺតស៊ូច្រើនបំផុត
ហើយគាត់រៀបការជាមួយភរិយាមានកូន៦នាក់ហើយលោកពូប្រកបរបរនេសាទដើម្បីចិញ្ចឹមកូននឹងប្រពន្ធ។

កះ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូជាលើកទី២ នាងខ្ញុំឈ្មោះញ៉ែម
សុគន្ធាជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូនៅក្នុងថ្ងៃនេះ
ពួកយើងសំភាសន៍នៅក្នុងភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា
ហើយពួកយើងសំភាសន៍នៅក្នុងខែមិនា ឆ្នាំ២០១៨

ការសំភាសន៍របស់លោកពូគឺជាការសំភាសន៍ជាលើកទី២ហើយលោកពូនឹងប្រាប់ពីកន្លែងដែលលោកពូបានខ្វះខាត
ហើយក៏ដូចជាកន្លែងដែលជាជីវិតរបស់លោកពូផ្ទាល់បន្ថែមទៀត
អ៊ីចឹងពូសូមប្រាប់ឈ្មោះពេញរបស់លោកពូម្តងទៀតណាស់ពូ?

ខ៖ ឈ្មោះអោម វិបុល បាទ!!

ក៖
ចាំ!!អ៊ីចឹងលោកពូពីមុនចូលដល់សង្គ្រាមនឹងរឿងអ្វីផ្សេងអ៊ីចឹងចង់ដឹងពីការសិក្សារបស់លោកពូសិនលោកពូបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ខ៖ អត់បានរៀនផង។

ក៖ អត់សោះម៉ង?

ខ៖ អត់សោះម៉ង។

ក៖ ម៉េចអ៊ីចឹងវិញ ដល់ពេលធំឡើងចូលដល់សង្គ្រាមម៉ងពូឬក៏ម៉េច?

ខ៖ ធំឡើងសង្គ្រាម ដល់ពេលធំឡើងគេបង្រៀននយោបាយយូរៗទៅ
រៀនអក្សររៀនចេះតាមគេ។

ក៖ ចាំ!!

ខ៖ តាមតែគេតាមតែឯងប៉ុន្តែអក្សរគេបែរមុខទៅណាទេ
ប៉ុន្តែគ្រាន់តែឥឡូវអាចសរសេរបានមើលបាន។

(មិត្ត)៖ឆ្លាតហើយអ៊ិចឹង។

ខ៖ កុំតែឆ្លាតប៉ុណ្ណឹងកុំអីងាប់តាំងពីយូហ្វ៎!!

ក៖ ចាំ!!ពូអត់ដែលបាន បានចូលសាលាសោះម៉ងពូណោះ?

ខ៖ អត់ទេ!!

កៈ ចាំ!

!ខៈ បានមកចូលមកចូលសាលាទ័ពសាលានយោបាយសាលាអីហ្នឹង។

កៈ ហ្នំ ពូគេរៀនពីអីគេវិញពូសាលានយោបាយ សាលាទ័ពអីវ៉ាន់ហ្នឹងហ្នំ?

ខៈ រៀនកាលសាលានយោបាយ
ធម្មតាអារឿងពាក្យថានយោបាយយើងពិបាកនិយាយណាស់!!

កៈ ហ៊ុំៗ!!

ខៈ បើនិយាយទៅពីរឿងការរៀនរឿងក្នុងការពង្រឹងមូលដ្ឋាន យើងវ៉ៃ
យើងនិយាយតែពីរឿងវ៉ៃខ្មាំងតែម្តង!!

កៈ ចាំ!!

ខៈ បាទហើយខ្មាំងសុទ្ធតែខ្មែរនិយាយអោយចំអញ្ចេះម៉ងទៅ
អ្នកស្តាប់ក៏សើចដែរមែនតើ!!ព្រោះញ៉ុមមិនដឹងគិតអាម៉េច!!ហើយកាលពេលជំនាន់នោះគេអោយញ៉ុមវ៉ៃ
ធម្មតាយើងរស់នៅក្រោមអំណាចរបស់ទឹកភ្លៀងហើយយើងដឹងហើយថាទឹកភ្លៀងយើងដឹងស្រាប់ហើយ ទោះបីយើងជៀសពីទឹកភ្លៀងរួចក៏ផឹកទឹកភ្លៀងដែរ
បាទសូម្បីតែទឹកទន្លេក៏ទឹកភ្លៀងធ្លាក់លើ ទឹកទន្លេក៏ទឹកភ្លៀងដែរ។

កៈ ចាំ!!

ខៈ ទឹកបឹងក៏វាជាទឹកភ្លៀងដូចតែគ្នា អីចឹងអ្នកណាក៏ដាក់មួយម៉ាត់ហ្នឹងក៏វាសមដែរ
រស់ក្រោមរដ្ឋអំណាចទឹកភ្លៀង។

កៈ ចាំលោកពូមានដែលមានក្តីស្រម៉ៃថាធំឡើងចង់ធ្វើឡើងចង់ធ្វើអីគេអត់ពូ?

ខៈ លោកពូគឺក្តីស្រម៉ៃរបស់លោកពូគឺផុតហើយ
វាក្តីស្រម៉ៃរបស់លោកពូកាលពីដើមអត់មានចង់ធ្វើអីទេ ចង់រៀនតែបើកឡាន
ប៉ុន្តែដល់ពេលបើកឡានវាមិនបានសំរេច ចប់ ស្រុកមានសង្គ្រាម
ហ្នំសូម្បីតែធ្វើដីក៏ធ្វើឡានដែរ។

កៈ ដីឥដ្ឋយកមកធ្វើឡានពូហោ?

ខៈ  បាទ!!

កៈ ចាំ!!

ខៈ  បប្ដូរមាត់សុទ្ធតែដីហ្នំ!!

កៈ អ៊ីចឹងពូសំរាប់ការសិក្សាពូបានប្រាប់ដែលពូបានរៀនផ្សេងទេអត់បានរៀនតាម!!

ខៈ  អត់បានរៀនសាលាទេ ព្រោះសាលាកាលពីជំនាន់នោះវាសុទ្ធតែសាលាសង្គ្រាម។

កៈ ចាំ!!

ខៈ  ហើយបើសិនជារៀនក៏មិនដឹងជារៀនស្អីរៀនតែរើសកគួររើសអីកាលជំនាន់ប៉ុល ពតហ្នឹង ហើយរៀនធ្វើកាន់កាំភ្លើង។

កៈ ចាំ!!

ខៈ មានតែប៉ុណ្ណឹង!!

កៈ ចាំ!!អ៊ីចឹងលោកពូសំរាប់ចូលដល់ជីវិតអាពាហ៍ពិពាហ៍របស់លោកពូវិញម្ដង!!

ខៈ  បាទ!!

កៈ  ម៉េចសួរអ្នកមីងហើយហើយក៏ចង់សួរខាងលោកពូដែរ
!!តើលោកពូរៀបការជាមួយអ្នកមីងគាត់ឈ្មោះអីគេដែរ?

ខៈ  ជួប សាម៉ៃ!!

កៈ  ចាំជួប ស្រម៉ៃ!!

ខៈ  ហើយលោកពូនិយាយចុះ និយាយកាត់ទៅចុះថាម៉ងទៅ លោកពូអត់បានរៀបទេ!!

កៈ ចាំ!!

ខៈ  លោកពូអត់បានការប៉ុន្តែលោកពូបានរៀប។

ក៖ ចាំ!!

ខ៖
ចុះធម្មតាប្រពៃណីខ្មែរយើង!!ធ្វើម៉េចក៏ត្រូវបានរៀបដែរណាស់គេនិយាយថាអារឿងខ្មោចស៊ីខ្មោចអីហ្នឹង។

ក៖ ហ៊ឺៗ!!

ខ៖ បាទមានក្បាលជ្រូកមនាមាន់មានអីហ្នឹង ចាស់ទុំគាត់ដឹងគាត់ឮ។

ក៖ ចាំ!!

ខ៖ ប៉ុណ្ណឹង!!

ក៖ ចាំពេលហ្នឹងមានថ្លៃជំនូនមានថ្លៃអីអត់ពូពេលរៀបពេលអីហ្នឹង?

ខ៖ ជំនូនអត់!!

ក៖ អត់ទេ!!

ខ៖ យើងអោយតែលុយគេទិញតែគ្រឿងតែគ្រៅទៅធ្វើអីធ្វើទៅ។ក៖ ចាំ!!ខ៖
យកមករៀបចំអីសំពត់ឆ្វេងស្តាំទៅ។

ក៖
ចាំលោកពូមើលនិយាយពីប្រវត្តិស្នេហារបស់លោកពូជាមួយនឹងអ្នកមីងបន្តិចមើលញ៉ុមឮយើញថាថ្លៃប៉ិគក់មួយហោ?

ខ៖ អត់ អត់
ដល់ប្រវត្តិស្នេហាទេប្រវត្តិញ៉ុមមុនដំបូងឥឡូវសួរពីអាកន្លែងទាហានហ្នឹងមកហើយ។

ក៖ ចាំចាំ!!

ខ៖ បាទសួរពីកន្លែងហ្នឹងមកវិញ។

ក៖ ចាំ!!

ខ៖ បានមកចូលដល់អារឿងកន្លែងស្មេហា៎!!បាទបាទ!!

ក៖ ហ្នឹងហើយ។

ខ៖ កាលហ្នឹង ញ៉ុមនិយាយកាត់ទៅចុះ!!

ក៖ ចា៎!!

ខ៖
ញ៉ុមនឹកឃើញថាម៉ែឪស្លាប់អស់ទៅហើយហើយមកមកស្រុកកំនើតនេះយើងគ្មានផ្ទះគ្មានសម្បែងគ្មានដីគ្មានធ្លីអីហា៎!!

ក៖ ចា៎!!

ខ៖ ហើយភូមិឃុំក៏គេមិនទទួលស្គាល់ថាយើងជាអ្នកនៅក្នុងភូមិឃុំហ្នឹងដែរ។

ក៖ ហ៊ឺៗ!!

ខ៖ ហើយខ្ញុំក៏ដើរតែលតោលញ៉ូមគ្រាន់តែដឹងថាតែប៉ុណ្ណឹង
ញ៉ុមទ្រាំមិនបានថាមិនដឹងដើរទៅរកអីធ្វើអីចុះប៉ុន៧៩(១៩៧៩)មែនប៉ុន្តែអាយុ១៩ឆ្នាំ
យើងពីបាកណាស់យើងអត់មានប្ដីអត់មានប្រពន្ធអត់មានកូនអត់មានចៅ
គេទៅខ្វះស្អីគេបើថាបងប្អូនគេលើកកូនគេលើអីអោយប៉ុន្តែតែពូអត់មានត្រូវការ
អត់មានចិត្តថាមកស្រលាញ់អ្នកណាអ្នកណាអីអត់!!បើអត់និស្ស័យហើយពូចេះតែដើរដើរដល់ពេលរួចទៅពូទៅវិញពូទៅធ្វើទាហានខាងចោរព្រៃមេរបស់ពូឈ្មោះអាសារឿតសារឿតហ្នឹង។

ក៖ ហ៊ឺ!!

ខ៖
ដល់ពេលរួចទៅអាគ្រាន់តែអារឿងបន្ដោកក្បាលព្រំហ្នឹងជំនាន់ហ្នឹងហើយពូក៏ត្រណាត់ត្រណែងទៅនៅហ្នឹងដល់ពេលរួចទៅនាំគ្នារត់ទៅថៃ
រត់ទៅថៃទៅដល់ភ្នំតាផ្ដេយួនពទ្ធ័ភ្នំតាផ្ដេមកវិញមកចាប់ពូ
ចាបពូមក៣០០នាក់ហ្នឹងប្រហែលជាសល់គ្នាតែ៤០នាក់ទេ!!បើកផ្លូវឈាមយួនបាញ់ចោលងាប់ទាំងអស់បាញ់ងាប់នៅភ្នំបាក់ នៅខាង

មកចាប់បានចាប់បាននៅភ្នំបាក់ហ្នឹងតែម្តងខាងគីឡូដុកខ្លាហ្នឹង មកល្អាងព្រៃកន្ទួតច្រឡំគ្នា
នៅសល់តែ៤០នាក់ ៤០នាក់វាដាក់នៅមួយឡាន
ញ៉ុមស្មានតែយួនយកខ្សែធំៗយកមកចងវាចងខ្សែឆែតីក្រហមយើងហ្នឹង ខ្សែប៉ុនអំបោះក្រមា
យកមកដល់វាអត់មានយកមកចងសម្លាប់មុខអោយយើងទេ
តែមួយសរសៃទេណាស់ចងមេដៃអីចឹងណាស់ដាច់បាញ់ចោលហើយតែដាច់បាញ់ទំលាក់ពី
លើឡានចោលហើយ ដល់ពេលនេះគេចងឆែតីក្រហម យើងចេះតែនេះហើយ
ចេះតែភ័យហើយ ដល់តែនេះដល់អាឡានវាក្រឡុកក្រលាក់ម៉េចក្រឡុកទៅ
ដួលបាសដៃបាសជើងគូទបាសម៉េចបាសទៅ!!

(មិត្ត)៖ កុំអោយតែដាច់ខ្សែ?

ខ៖ បាទកុំអោយតែដាច់ខ្សែហ្នឹងទៅ!! យកញ៉ុមយកមកដាក់នៅមន្ទីរថ្កោលនៅប្រាសាទនេះ
ដាក់គុកនៅមន្ទីរថ្កោល។

ក៖ ពេលហ្នឹងទោសពៃអីគេពូបានអញ្ចឹង?

ខ៖ ហាំ!!យើងខាងខ្មែរក្រហម។

ក៖ ហ្អំៗ!!

ខ៖ យើងឈ្លើយសឹកហើយ មនុស្សចាញ់សង្គ្រាមអីចឹងហើយ!!

ក៖ អូយហ្នឹងហើយ អូយពូ!!និយាយថានិយាយមកគួរអោយខ្លាច!!

ខ៖ ចុះបើមើលសល់តែ៤០នាក់គិតមើលទៅ!!

ក៖ ពេលហ្នឹងពូទាហានខ្មែរក្រហមហើយលន់ នល់ហោ?ហ៊ីពួកវៀតណាមហោ?

ខ៖ លន់ នល់ហោ!!យួន !

ក៖ ហ្នឹងហើយ !!

ខៈ  វៀតណាម!!ចងខ្សែតីយកមក ដល់ពេលយកមកដាក់នៅគុកមន្ទីរថ្កោល ដាក់ពូ
ពូល្បិចខូចដែរ ហ្នឹល្បិចជំនាន់ហ្នឹងថា
ល្បិចថាយើងបើនិយាយពីជំនាន់ឥឡូវកាលមួយហឹកនោះញ៉ុមអត់ទាន់ស្គាល់ព្រះហាំ!!

កៈ ហ្ន៎!!

ខៈ
កាលមួយហឹកហ្នឹងដូចមានព្រះជាប់ខ្លួនបើយើងនិយាយទៅដូចគុណម៉ែគុណឪគាត់ជួយហាំ!!
ញ៉ុមរត់រួចហាំ!!ដាក់ញ៉ុមបានតែមួយអាទិត្យទេ!!ពេលស្មើរហ្នឹងអ៊ីចឹងហិអារាងព្រលប់ជាងហ្នឹង
បន្តិចហិ
ប្រជាជនគេនៅស្រុកណាអ៊ីចឹងមកស្រុកវិញហាំ!!មកស្រុកកំណើតខ្លួនឯងវិញនោះ!!មកពីបាត់
ដំបងដើរមករុញដើរមក
រុញរទេះរុញអីហ្នឹងខ្លះគេដាក់រទេះដាក់អីខ្លះគេដើរមកពីបាត់ដំបងដើរមកខេត្តកណ្តាលយើងវិ
ញ ខ្លះនៅខេត្តស្វាយរៀងទៅស្វាយរៀងអាខ្លះនៅព្រៃវែងទៅព្រៃវែងអ៊ីចឹងទៅណាស់!!

កៈ ចាំ!!

ខៈ  ដល់ពេលដល់ថ្មើរហ្នឹងគេអោយមកងូតទឹក ប្រហែលខ្វង់ថ្មើរហ្នឹង
ប្រហែលជាម៉ោង៥កន្លះហ្ន៎!!នាំគ្នាមកមុជ គេធំៗគេមុជជុំគ្នា ចំនែកញ៉ុមញ៉ុមមុជតែឯង
ញ៉ុមនឹកឃើញអារឿងឆ្ងាយតែឯងនោះ ក្រឡេកមើលទៅប្រជាជនប្រហែលប្រវែងហ្នឹង
ចុះនៅជិតថ្នល់។

កៈ ចាំ!!

ខៈ  ប្រជាជនគេកំពុងដើរមកស្រុកញ៉ុមទៅដល់មុជ
ធ្វើអារបៀបស្រាតខោមុជទឹកនោះហើយអាស្រះគេនៅមុខមន្ទីរថ្កោលហ្ន៎!! កន្លែងថ្កោល
ថ្កោលមន្ទីរថ្កោលហ្នឹង គ្រាន់តែធ្វើអោនស្រាតរត់ចូលទៅ
រត់ចូលទៅប្រជាជនមកថ្នល់ជាតិមកថ្នល់ជាតិវាបាញ់ម៉េចកើតបើវាបាញ់មិនត្រូវប្រជាជន។

កៈ ហ្ន៎ហឹបទឹកម៉ង?

ខៈ  ញ៉ុមអត់ហឹបទឹកទេ
គ្រាន់តែធ្វើអោនៗតែក្បាលមានដោះអាវនេះណា!!ធ្វើអោនតែក្បាលហ្នឹងហាំ!!អោនក្បាលធ្វើដូ

ចខ្លួនអីចឹង អោនក្បាលធ្វើដូចមុជទឹកអីចឹងណាស់!!
ដូចដោះខោអាវអីចឹងណាស់!!ធ្វើដូចស្រាតខោអីចឹងណាស់
គ្រាន់តែអោនក្បាលតែបន្តិចវាមិនទៅចាប់ផ្លឹកអីញ៉ុម ហើយញ៉ុមវាម្យ៉ាងញ៉ុមតូចជាងគេផង
គេសុទ្ធតែដុះពុកមាត់អស់ហើយញ៉ុមមិនទាន់ដុះផងកាលពេលជំនាន់ហ្នឹងនោះហាំ!!វាថាញ៉ុម
នៅក្មេងវាមិនសួរអីវាមិនសួរល្បិចហាំ!!គេមិនទាន់ដឹងថាញ៉ុមក្មេងល្បិចសង្គ្រាមចង់ងាប់
ដល់តែអីចឹងញ៉ុមក៏ធ្វើអោនក្បាលអោនក្បាលចុះរត់ទៅប្រជាជន
ចុះប្រជាជនរាប់ម៉ឺននាក់ហាំ!!មកពីបាត់ដំបងមកពីអីវិញនោះ!!

កះ ហ៊ឺៗ!!

ខះ បាទដល់តែរត់ចូលទៅនេះគេហ្នឹងរត់ចូលមកប្រជាជនគេស្មានតែញ៉ុមបែរមុខមកកើត
ឃើញញ៉ុមញ៉ុមរត់រត់ទៅកើតដល់ពេលញ៉ុមរត់ទៅញ៉ុមទៅលិចវិញ!!
ទៅលិចធ្លាក់ដល់អន្លង់វិល
ទៅដល់ដោះខោអាវអស់រលីងចុះខោអាវយើងនេះនោះអាខោអាវអាពតនៅក្រៅចេះតែបានពា
ក់អាអាវយឺតខៀវអាដៃត្រឹមនេះ។

កះ ពេលឆ្នាំប៉ុន្មានពូពេលហ្នឹងឆ្នាំបែកហើយពូហោ?

ខះ កាល៧៩(១៩៧៩) ហើយហ្នឹង ។

កះ ហ្ហ៎!!

ខះ កាលហ្នឹងចាប់បាន ។

កះ អីចឹងពូកាលហ្នឹងបានធ្វើទ័ពរបស់ខ្មែរក្រហម?

ខះ ពូធ្វើទ័ព ទ័ពព្រៃតើ!!ទ័ពមិនមែនខ្មែរក្រហមទេជំនាន់ហ្នឹង!!

កះ ហ្ហ៎!!

ខះ បើនៅដល់តែឥឡូវវិញគេហៅទ័ពបក្សម៉ូលីនីកាបាត់ទៅហើយ!!

កះ ម៉េចវិញទៅពូអាហ្នឹង?

ខ៖  ពួកនេះហាំ ពួកទ័ព សឺន សានហាំ!!បាទនៅខាងសឺន សាន
ព្រោះមួយហឹកហ្នឹងនៅខាងចោរព្រៃនៅឡើយ!ជួបយួនបាញ់យួន
ជួបខ្មែរក្រហមបាញ់ខ្មែរក្រហម។

ក៖ ហ៊ឺៗ!!

ខ៖  ឡើងអាណាធិបតេយ្យម៉ងខ្លួនឯងហ្នឹង។

ក៖ ចាំ!!

ខ៖  នាំគ្នាឆ្លងថារត់មកថៃ មានបានរត់រួចណា យួនខ្វៀងសុទ្ធតែរុកគ្រោស!!

ក៖  ពេលហ្នឹងទៅ១០០នាក់ពូហេ?

ខ៖  ៣០០នាក់។

ក៖  ៣០០នាក់?

ខ៖  បាទ !!មួយវរសេនាតូច!!។

ក៖ ចាំ!!

ខ៖  នៅតែអត់ឈ្មោះវា វាឈ្មោះម៉េចបើយើងចាញ់
បើនិយាយទៅកាលហ្នឹងប្រជាជនក៏គេមិនគាំទ្រដែរ ហើយបើញ៉ុម
បើញ៉ុមនៅពាក់ខោអាវខ្មៅនៅឡើយមានទាន់មានខោអាវម៉ូលីនីកា
មិនទាន់មានខោអាវប៉ាវ៉ាឯណាស្លៀក!! នៅឡើយហ្នឹង ដល់យើងទៅដល់ជំរុំ
ទៅដល់ជំរុំបានគេមានខោអាវ បាទបានគេមានខោអាវអោយយើងស្លៀក
ដល់ពេលហ្នឹងនៅមានខោអាវខ្មៅនៅឡើយអាហ្នឹងគេថាទ័ពអាពត !!

ក៖ ហ៊ឺៗ!!

ខ៖  កុំគេស្គាល់ គេសំគាល់ថារូបវិមានឯករាជ្យទេ
រូបវិមានឯករាជ្យសាក់ប៉ុនហ្នឹងហិ!!ដាក់នៅហ្នឹងក្បាល
មួកស្លឹកក៏ដាក់នៅប៉ុណ្ណឹងដែរ!!ធ្វើម៉េចកុំអោយបាត់

បើសិនជាអត់មួកទេដាក់នៅហ្នឹងហោប៉ាវអាវយើងដាក់ចងបន្ដោកនឹងហោប៉ាវអាវ យកម្ទុលយកមកខ្មៀស។

ក៖ តែអញ្ចឹងគេច្រឡំថាប៉ុល ពត?

ខ៖ បាទប្រជាជនគេថាប៉ុល ពត គេកំពុងស្អប់ប៉ុល ពតផងរត់មិនរួចដល់ពេលគេចាប់បានទៅ ដល់បានពេលឃើញអញ្ចឹងដល់ពេលឃើញញ៉ុមអញ្ចឹងញ៉ុមនិយាយបកមកវិញមកដល់ត្រឹមអា កន្លែងញ៉ុមរត់មកនេះហ្នឹងបុកអង្គរមកឯស្រុកហ្នឹងញ៉ុមទៅដល់ឯអន្លង់វិលហ្នំទៅដល់អន្លង់វិល ហ្នឹងហើយម្នាក់ឯងហ្នឹងហាំ!មានស្អីគ្រាន់ស្ងោរសាគូរើសអំបែងពាងស្ងោរហ្នឹងមានអីមានឆ្នាំង មានចាន
ស្ងោរទំរាំតែនឹងឆ្អិនអើយ!!ប្រហែលជាមិនដឹងប៉ុន្មានដប់ម៉ោងទេ!!បើនិយាយស្ងោរសាគូ បើស្រូវទៅយកនៅភ្នំតាផ្ដេហ្នំ!! ឡើងយកតាមគេតាមឯង
ដល់ពេលមើលទៅទាល់ច្រកពេកដាច់ចិត្តហ្នំទៅគិតអីជ្រូកមួយក្រោលញ៉ុមស្ដាយដែរ បើសិនជា
ចុះបើសិនជាដឹងថាអញ្ចឹងបើសិនជាមានប្រពន្ធមានកូនសុខចិត្តទៅនៅហ្នឹងទ្រុងជ្រូកតែម្ដង ស្រួលបាត់ បាទទ្រុងជ្រូករាប់រយហាំ!!ហើយធាត់ៗណាស់
សុខចិត្តបើទ្រុងហ្នឹងប្រលែងអោយជ្រូកហ្នឹងចេញមក
កាប់ជ្រូកហ្នឹងមួយយកសាច់យកមកស្រុកជ្រូកមួយមានអី
វះយកតែសាច់ថ្លើមហ្នឹងតិចតួចហើយសាច់ហ្នឹងតិចតួចយកមកប្រលាក់ទៅរំលីងទៅដាក់ក្រ មែលទៅណាស់ ហើយអង្ករខំបុកឡើងបានមួយស្បោង មួយស្បោងប៉ុននេះ
ប្រហែលមួយតៅដែរ មួយស្បោងមកអាពាក់ឈៀង!!ក៖ ចាំ!!ខ៖
គាត់ឃើញអាស្បោងប៉ុណ្ណឹងដែរទេ?ដែរអាពាក់ឈៀងអញ្ចេះហ្នឹង??

(មិត្ត)៖ហ្នឹងហើយ។

ខ៖ បាទហ្នឹងហើយពាក់ឈៀង ពាក់ឈៀងមួយចំហៀងកន្លះតៅមួយចំហៀងកន្លះតៅ បានតែក្រមែលហ្នឹងមួយហ្នឹង
ដល់ពេលម្ហូបដោះម្ហូបហ្នឹងចេញទៅយកក្រមែលហ្នឹងដាំបាយទៅពីព្រឹកទុកដល់ល្ងាច ម្នាក់ឯង ដល់ពេលមកដល់ស្រុកបងប្អូនគេមានស្គាល់អី
គេអត់ស្គាល់ដល់ពេលសួរទៅស្រាវជ្រាវពីប្រវត្តិរូបគេត្រូវគេសួរហាំ!!

ក៖ ចាំ!!

ខ៖ គេដឹងថាញ៉ុមកូនអ្នកនេះកូនអ្នកនោះ គេនាំគ្នាស្រែកយំឡើងពេញផ្ទះ
គេស្រែកយំពេញតែផ្ទះគេថាអើយគេថានៅមួយពូជនៅសល់មួយដៃរអញ្ចេកដល់ពេលអញ្ចឹង
ញ៉ុមនឹកគិតយូរៗទៅមិនដឹងទៅនៅឯណាទេ
បើគ្មានផ្ទះគ្មានសម្បែងអីនៅបងប្អូនមែនប៉ុន្តែយើងគ្មានដីគ្មានធ្លីហាំ!!

(មិត្ត)៖ មួយពូជសល់មួយ!!

ខ៖ បាទ!!អ៊ំញ៉ុមថាយកប្រពន្ធទៅ !!ញ៉ុមថាញ៉ុមយកធ្វើអីចំណាស់នេះនោះនៅក្មេង
ញ៉ុមអត់យកទេ ថាបើសិនជាញ៉ុមយកប្រពន្ធគេអោយដីគេអោយធ្លីហើយភូមិឃុំគេអោយហាំ!!

ក៖ ចាំ!!

ខ៖ ប៉ុន្តែញ៉ុមអត់ព្រមញ៉ុមចេះតែដើរទៅទៅ ញ៉ុមដើរទៅធ្វើទាហានទៅ
បកមកធ្វើទាហានវិញ!!ដល់ពេលរួចទៅ
កាលមួយហឹកហ្នឹងញ៉ុមរ៉ៃនៅបរហ្នឹងរ៉ៃពួកជំរុំរ៉ៃពួកអីហ្នឹង
អើយដើរអត់បាយក្រហាយទឹកណាស់ ជូនកាលមួយអាទិត្យហ្ហ៎!!ញ៉ុមប្រាប់
តិចអត់ជឿញ៉ុមទៅមើម្កាក់យើងហ្នឹងអាម្កាក់ព្រៃយើងហ្នឹងដកមកមើមប៉ុនៗនេះមើមទិលមើម
ម្កាក់ព្រៃ ជាពិសេសមើមរកា
ឃើញអាកូនរកាមើមឃើញអាសន្លឹកខ្មៅកំពស់ៗនេះហ្នឹងប្រវែងៗហ្នឹង ថាប្រវែងចុះ!!

(មិត្ត)៖ យកមើមហ្នឹងហូបនៅហេ?

ខ៖ ជីកមកយកមកហូបមកស្រួលពោះតើ!!យើងអ់តបាយមួយអាទិត្យអីហើយ ហេវ!!
ហ្ហ៎ខ្លាំងជានំប៉័ងដាក់សាច់ទៀតហ្ហ៎!!នំប៉័ងដាក់សាច់ដាក់ប៊័រអត់ស្មើហ្នឹងមើមហ្នឹងផង!!

ក៖ ហ៊ឺៗ!!

ខ៖ ហូបហូបធ្វើម៉េចអោយបានតឹងអោយបានណែនណែនក្រពះហ្នឹង
បើយើងមិនហូបយើងអត់ ដល់ពេលអញ្ចឹងទៅទឹមបានមកធូរមកជិតបានប្រពន្ធញ៉ុមហ្នឹង
ដល់ពេលបានមករៀន
គេដកទៅរៀនឯណោះគេដកទៅរៀននៅឯណោះបានញ៉ុមរៀនខាងកាំភ្លើងធំហ្នឹង

គឺញុំមចេះខាងហ្នឹង បើញុំមមួយហឹកហ្នឹង គេបើកអោយ ប៉ុន្តែញុំមនិយាយកាត់ចោលទៅ
គេអោយញុំម មុនដំបូងគេថាអោយញុំមទៅរៀនឡានហើយកុំអីអឺចឹងទៅរៀនបើកឡានហាំ!!

កៈ ជិតបានបំពេញក្តីស្រម៉ៃហើយពូហេ?

ខៈ បាទ!!ញុំមថាហេតែប៉ុននេះបំណងញុំមបានល្អហើយ
ស្រាប់តែរួចគេមិនអោយញុំមទៅរៀនឡានគេអោយញុំមទៅរៀនកាំភ្លើងធំ
បាទដល់ពេលអីចឹងគេថាអិចឹងញុំមមានតែចូលកងរុកគ្រោសទៅញុំមខ្ជិល មិនបាច់ទេ
ម៉ាតែពួកម៉ាក់ញុំមមួយអាហ្នឹងវាសុទ្ធតែនេះហាំ
អាហ្នឹងពេលញុំមត្រើសដែរជំនាន់ហ្នឹងញុំមនៅកាន់គរនៅឡើយគ្រាន់តែកូនទាហានញុំម១០
៧នាក់!!

កៈ ហ៊ឺៗ!

ខៈ ដល់ពេលអីចឹងទៅគេដកញុំមមករៀននៅសាលា ង៥០ ញុំមវាបញ្ហាច្រើនពេក
ង៥០ហ្នឹងវាយើងពិបាកណាស់
គេក៏វាមនុស្សទោះបីថាគេអាក្រកក៏គេមនុស្សគេល្អក៏គេមនុស្សដូចតែគ្នា
ដល់ពេលបញ្ហាអោយគ្នាអ្នកខ្លះគេរត់មកស្រុកវិញណាស់ចុះដឹងស្រាប់ហើយមីន
ដាច់តែជើងដាច់តែដៃហើយមានទៅងាប់អីពួក៧៩ឯណា
ងាប់ងាប់ដេញតែអាពួកទាហានចាប់បញ្ជូនទៅហ្នឹង
ញុំមវាខ្លះអាខ្លះគ្នាឃំគ្នាស្រែកញុំមអាណាគ្នារត់រួចរត់ទៅប្រាប់ផ្លូវអោយរត់ទៀតហ្វាំ!!ចេះតែអោ
យមកវិញ ដល់ពេលនេះទៅ តានេះគាត់ថាបុលអត់កើតទេ បើកាន់ជើងកូនទាហានអីចឹង
!!មិនទៅកាន់ជើងអីកូនចៅញុំមទេគេក៏ចង់រស់ អ្នកគេចង់រស់ចង់រស់ទៅ
!អីចឹងប្លែងធ្វើទាហានអត់កើតទេ
ធ្វើមេទាហាន!!ញុំមមិនបាច់ទេមួយហឹកហ្នឹងញុំមទាស់ជាមួយ ជិន តូ មេបញ្ជាការហ្វឹកហ្វឺន
ហាអើរប្រធានផែនការស្នងការហ្វឹកហ្វឺនទៀត!!ជំនាន់ហ្នឹងញុំមឡើងមកប្រជុំនៅដីអិនហាំ!!
ក្នុងមួយខែញុំមឡើងមកប្រជុំនៅហ្នឹង៣ដង។

កៈ ចាំ!!

ខៈ ញុំមឡើងមកភូមិដីអិន នៅភ្នំពេញហ្នឹងហាំ!! ហើយញុំមនៅ
ញុំមនៅឈរជើងនៅភ្នំស្រួចទៀតប៉ុន្តែក្នុង១ខែញុំមឡើងមក៣ដង

ទំនាស់គ្នាអារឿងបើកគោលនយោបាយហ្នឹង ហើយម្យ៉ាងទៀតរឿងខ្មោចទៀត
អារឿងខ្មោចស្លាប់ហ្នឹង ដល់ពេលខ្មោចស្លាប់ ដល់ពេលអញ្ចឹងបានញុំមតូចចិត្ត
ញុំមតូចចិត្តខ្លួនញុំមញុំមតូចចិត្តខ្លួនញុំមញុំមនឹកឃើញថាហ៊ីតស្វ៊ ក៏តស្វ៊អត់ប្រយោជន៍ដែរ
គ្នាស្លាប់ គ្នាស្លាប់គ្រាន់តែសុំយកឆ្អឹងយកមកផ្ទះមកអោយឪពុកម្ដាយអត់
គ្រាន់តែឈ្មោះយកមកអោយនៅហ្នឹងឪពុកម្ដាយនៅស្រុកហ្នឹងក៏អត់ដែរ!!

(មិត្ត)៖ គ្រាន់តែអញ្ចឹងសោះ!!

ខ៖ បាទ!! គេអត់អោយមានអោយ
បើកាលណា!!ជំនាន់ហ្នឹងគាត់ដឹងដែរហី(សួរទៅមិត្ត)!!បើកាលណាយកពីថ្មភ្ជូមិទៅកូនអ្នកនេះ
ស្លាប់បាត់ហើយចុះអានៅហ្នឹងក្រោយហ្នឹង មានអាណាចាប់បានទៅទៀត
មានពីណាហ៊ានស្លាប់ទៀត បើទៅស្លាប់ទៅស្លាប់ហ្នឹង!!

ក៖ ហ្ន៎!!

ខ៖ ចុះវ៉ៃ ដូចវ៉ៃនៅជុំរុំ៧ ជុំរុំ ដូចជុំរុំសាយប៊ី ជុំរុំនងចាន់
នងអីហ្នឹង!!ស្មានតែទាហានខ្មែរយើងងាប់តិចណាស់ហី!!ងាប់ឡើងរនាលនៅនឹងដីហ្ន៎ញុំមប្រាប់!! ងាប់ឡើងរលហ្ន៎!!នៅសល់តែពួកអាទាហានចាស់ៗហ្នឹង
អញ្ចឹងបានញុំមនឹកឃើញថាបើអ្នកណាគេចរួចគេចទៅ
មកក្រោយមកបានគេដកញុំមយកមករៀននៅង៥០នេះ នៅដីឥដ្ឋនេះ
ញុំមថាហ្ន៎បានមកនៅភ្នំពេញហើយ មករៀនបានតែប៉ុន្មានខែគេដឹងថាញុំមនេះហើយ
ណោះទៅអង្គភាពវិញ នៅអង្គភាពខ្មែរក្រហមកំពុងតែវ៉ៃដុត
វ៉ៃដុតឡើងឆេះថ្កោលៗតែម្ដងហ្នឹង
បាទវាវ៉ៃហើយវាដុតផ្ទះចោលកំទេចចោលទាំងអស់ហ្នឹងហា៎!!បាទហើយយើងឯណាទៅនេះ
លោកអើយ តែវាវ៉ៃហើយវាដុតភ្លើងអោយហើយ
មើលគ្រាន់តែវ៉ៃអង្គភាពញុំមគ្រាន់តែវ៉ៃហើយពឹប ផ្ទះ១៦ខ្នងវាដុតចោលទាំងអស់ផ្ទះទ័ព
ឡើងភ្លឺមួយចំហៀងមេឃហ្ន៎!! ឡើងភ្លឺ
បាញ់បញ្ជេះបាញ់អីហ្ន៎ឡើងខ្វេចខ្វីអីអស់ហើយ!!ហើយអ្នកណាមិនចង់រស់ជំនាន់នោះ
ទាល់តែពេលមិនដឹងគុណបុណ្យអាម៉េចគេនឹកឃើញ គេថាហ៊ីអោយអាបុលទៅរៀនតែម្ដងទៅ
រៀនខាងដាក់កុងម៉ងទៅអត់កើត ទៅរៀនដាក់កុងទៅរៀនតែ១២ឆ្នាំទេគេប្រាប់ញុំមហ្នឹងហា៎!!

ក៖ ១២ហោ!!

ខ៖  បាទ!!រៀនតែ១២ឆ្នាំទេ។

ក៖  មើលតែ១២ឆ្នាំហ្នឹង១២ថ្ងៃ!!

ខ៖  បាទ គេថាទៅរៀនតែ១២ឆ្នាំទេ ញុំមថា១២ឆ្នាំក៏រៀនដែរកុំភ័យ
ធ្វើម៉េចអោយតែរៀននៅនយោបាយអោយមកដល់ភ្នំពេញសិន!!

ក៖  ដាក់កុងហ្នឹងម៉េចទៅពូ?

ខ៖  អើយដាក់កុងហ្នឹងដឹងស្រាប់ហើយ ធម្មតាអាយើងណាទាហានដាក់កុង
កន្លែងណាដែរលវ៉ែខ្លាំងមែនទែន ពួកទាហានដាក់កុងហ្នឹងចូលហើយ។

ក៖  វ៉ែមិនបែកចូលម៉ងហោ?

ខ៖  បាទ!!ដូចអារីខនដូចរបស់ទាហានអាមេរិកកាំងហ្នឹងអ៊ីចឹង។

(មិត្ត)៖ អាហ្នឹងអាទ័ពឆ្មើមគេហ្នឹងហ្ន៎??

ខ៖  បាទអាហ្នឹងហើយពួកទព័ចោរ ចោរមានចេះមកពីណាទេ ចេះមកពីអាពួកដាក់កុងហ្នឹង
ឡើងជញ្ជាំងផ្ទះ៤ ៥ម៉ែត្រ ៤ ៥ជាន់អីឡើងរួចហ៎!!

ក៖  ចំសាហាវ??

ខ៖  បាទ!!អាហ្នឹងឡើងរួចហ៎ កងភ្លើងកងអីហាត់រៀនហ្វែងតាំងពីក្បួនចោរក្បួនអីទាំងអស់
អញ្ចឹងៗកូនៗហ្នឹងថាប៉ាអីបានចេះទៅធ្វើអីអញ្ចឹង!!
អារៀនបាញ់ឡាមបាញ់អីយកលុយតាមហោប៉ាវខោគេហ្នឹងគឺចេះទាំងអស់
បាញ់យកឯកសារឯកអីហ្នឹង ដូចអាបាញ់ឡាមយើងហ្នឹងនោះ
បាញ់ដាក់ទឹកអាស៊ីតបាញ់ដាច់ពិត មិនដឹងទេ!!

ក៖ ហ្ន៎!!

ខ៖  បើមនុស្សស្រីអីល្អមៗបាញ់ដាច់សក់ហុយសំពោងឥឡូវហ្នឹង។

កៈ ពូនៅចាំទាល់តែឥឡូវហោ?

ខៈ អត់ចាំទេ។

កៈ ភ្លេចអស់ហើយអញ្ចឹង?

ខៈ វាស្ពឹកស្រពន់អស់ហើយដៃជើងសូម្បីតែរត់ត្រឹមតែ១០ម៉ែត្ររត់លែងរួចហើយហ្នឹង។

កៈ ពេលមុនមិនបាច់ទេពូហោ!!ស៊ីផុយហ្នូពូហោ?

ខៈ ហ្នំពេលមុនវិញហ្នំប្រហែលចុងត្នោតនោះវិញ !!ស្រវឹងស្រាលោតពីលើចុងត្នោតហ្នឹងតើ!!និយាយលេងអីញ៉ុមនិយាយមែនណាស់។

កៈ ហើយលោតមកអត់អីដែរ?

ខៈ វាអត់អី កំពិតតែដីមនុស្សមានកំពិតអី!!

(មិត្ត)៖ព្រោះដីខ្សាច់?

ខៈ ហោដីខ្សាច់ឯណាដីនេះតើទៅមើល!!

(កូន)៖ ដីផ្លូវ!!

ខៈ ទៅមើលដើមត្នោតមិនឃើញ!!

កៈ ពូចេះវិជ្ជាសំរាលខ្លួនអីហោ?

ខៈ ហ៊ីសំរាលអី សំរាលរឿងស្រាហ្នឹង តែស្រាចូលខ្លួនវាចេះតែទៅហើយ។

កៈ ហើយអត់បាក់ឆ្អឹងបាក់ឆ្អែងដែរពូ?ត្នោតកំពស់ប៉ុន្មាន?ខ្ពស់?

(ប្រពន្ធ)៖ នោះដើមត្នោត!!

(កូន)៖ ក្រោយនេះ!!

ខៈ ដើមត្នោតគេធ្វើរាល់ថ្ងៃ(គេធ្វើយកទឹកត្នោត)។ល្មមតែលោតមក បើយើងមនុស្ស លោតមកបើសិនជាក្បាលដាំមកក៏វាអស់ដែរ!!

កៈ  តែចេះលោតមកអោយវាតាមសំរូល។

ខៈ  អាហ្នឹងវាធម្មតា!! ចុះត្នោតហ្នឹងកំពស់ចុងស្វាយតើ!!

កៈ  ចាំ!! ហ៊ីប៉ុណ្ណឹងខ្ពស់ឡើង !!

ខៈ បាទ!!

កៈ  ឃើញអញ្ចឹងធម្មតាទេ តែបើឡើងទៅហ្នំបានខ្ពស់!!

(មិត្ត)ៈ ហើយកូនចៅឃើញផ្អើលឆុលទៅ?

ខៈ  គេនាំគ្នាទៅមើលទៅ!!ដល់ពេលឃើញញ៉ុមដើរគេនាំគ្នាសើចដែរហ្នឹង
ហើយចុះម៉េចទៅអញ្ចឹង!!

(មិត្ត)ៈ ក្រោកដើរពីព្រងើយទៅ?

ខៈ
បាទ!!អញ្ចឹងបានថាប្រវត្តិពូនិយាយទៅហ៊ីអោយនិយាយវិញសឹងទេអោយនិយាយមួយអាទិត្យ
ហ្នំ!!និយាយមិនអស់ទេ!!

កៈ  ឥឡូវដល់មីង ម៉េចវិញបានដល់មីងនេះ ម៉េចបានដល់មកជួបមីងវិញ?

ខៈ បាទជួបមីងហេ?

កៈ ចាំ!!

ខៈ  មកដល់ដំបូងឃើញទូរទស្សន៍ មកដល់ស្រុកគេចុះគេមានបញ្ចាំងវីដេអូ
ចុះញ៉ុមកាលនៅណោះមានវីដេអូ មានស្អី
មកដល់ឃើញគេនាំគ្នាដើរសប្បាយដើរអីណាគេទៅ!!ឃើញយាយគាត់រាងស្អាតផង!

កៈ  មិនមែនស្គមដូចឥឡូវណាហី?

ខៈ  បាទ!!ហ៊ីពីដើមយាយអត់ទេ បើមិនអញ្ចឹងគេដាក់រហ័សនាមគេដាក់ហៅសុជាន់ម៉ៃទេ!!

កៈ  ហ្នំសាហាវម៉ង!!

ខ៖ អត់ទេអត់មីងពីដើមមិនមែនអ៊ីចឹងណា!!ទៅនិយាយលាក់បាំងអី!!

ក៖ ចាំ!!តែដោយសារឥឡូវហូបម្ហូបរើសពេកហើយគេងអត់លក់!!

ខ៖ ម្ហូបអីផឹកស្រាជ្រុលហាំ!!ផឹកស្រាភ្លេចបាយ ។

ក៖ ហ្នំ!!

ខ៖ ដូចតែញ៉ុមដែរហ្នឹងហាំ!!

ក៖ ម្យ៉ាងម្នាក់ទេហេពីរនាក់ប្តីប្រពន្ធ?

ខ៖ បាទហ៊ុប្រពន្ធផឹកប្តីក៏ផឹកដែរ!!អាហ្នឹងនិយាយលាក់បាំងអី!!

ក៖ ចាំ!!

ខ៖ ញ៉ុមមិនដែលនិយាយភូតទេ!!សួរបងគឹមហាក់ដឹងហើយ
បើអារឿងផឹកស្រាវិញសុំទោសហើយ មួយថ្ងៃ៣លីត្រអីហ្នំ!!ញ៉ុម៦លីត្រផឹកមួយម៉ោងកន្លះ
ផឹកពីរនាក់ហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖
ដល់ញ៉ុមមកឈប់អ៊ីចឹងគេឆ្ងល់គ្រប់គ្នាតែមិនដឹងថាយ៉ាងម៉េចទោះបីញ៉ុមថាយ៉ាងណាយ៉ាង
ណាអីក៏ដោយញ៉ុមមិនមែនថានិយាយអោយលើកមោទនភាពទេណាស់!!

ក៖ ចាំ!!

ខ៖ តែទោះយ៉ាងម៉េចក៏នៅមានអារម្មណ៍មួយនៅក្នុងខ្លួនដែរ
ដូចមានវិញ្ញាណមួយនៅក្នុងខ្លួនហ្នឹង។

ក៖ ចាំ!

ខ៖ បើកាលណាយើងហូបទៅវាអត់
បើកាលណាយើងហូបទៅវាសុខភាពមិនល្អបើកាលណាយើងហូបទៅវាជះអាធាតុលើអ្នកនា

ក់ជិតខាង អញ្ចឹងបានញុំមនឹកឃើញថា
បើជៀសជាងខ្មាសដល់ញាតិជិតខាងលុះគ្រាតែបើយើងឈប់ហូបគេនាំគ្នាចូលចិត្ត!!បាទ!!ឥឡូវអញ្ចេះនិយាយត្រលប់មកវិញកាលមួយហ៊ឹកជួបអ្នកមីង!!

ក៖ ចាំ!!

ខ៖ ហ្នឹងពូទៅមើលវីដេអូ ទៅមើលមើល ស្គាល់គ្នា ស្គាល់គេហ្នឹងហា!!ឃើញមុខគេ
ប៉ុន្តែឃើញបានតែម្តងហ្នឹងនឹកឃើញថា ហែក្មេងនេះគ្រាន់បើជំនាន់ហ្នឹងគេនៅតូចដែរនោះ
មើលក្មេងនេះគ្រាន់បើហើយញុំមវាចាស់ហើយអាយុ២៦ឆ្នាំហើយ។

(មិត្ត)៖ ហើយគាត់អាយុប៉ុន្មានកាលស្រលាញ់?

ខ៖ គេប្អូនញុំម៩ឆ្នាំ។

ក៖ ចាំ!!

ខ៖ គេ២២!! ដល់តែពេលញុំមមើលទៅថាហេខ្ជិលហើយម្យ៉ាងគេថាហេទៅយកធ្វើអី
ម្តាយក្រចង់ងាប់រកបាយហូបមិនបាន ក្នុងមួយខែលេងបបរហូបចង់១០អីអញ្ចេះ។

ក៖ ហុឺៗ!!

ខ៖ ចុះមានអីហូបអត់!!ម្តាយអត់ចេះរកអីផងហ្នឹងបេះតែត្រកួនអីហ្នឹង
បេះត្រកួនយកទៅលក់នៅផ្សារតាខ្មៅជួនកាលដាច់ជួនកាលអត់
ជួនកាលទៅរាវលៀសទៅរាវគ្រុំអីហ្នឹងនៅនឹងកោះហ្នឹងទៅ !!

ក៖ ហុឺៗ!!

ខ៖ ញុំមនឹកឃើញថាហុឺវាមិនអីទេ ផ្ទះអត់មនុស្សប្រុសវាអញ្ចឹងហើយ!!
ទាល់តែញុំមមាននប្អូនថ្លៃញុំមមួយប្អូនថ្លៃញុំមនៅនោះបានប្អូនថ្លៃញុំមបានវាស្រលាញ់ញុំមរហូតដល់សព្វថ្ងៃហ្នឹងវានៅតែគោរពញុំមហ្នឹង!!

ក៖ ចាំ!!

ខ៖ តាំងពីវានៅជំទង់នៅទូចដល់ឥឡូវដល់តែកូន៤ ៥ ញ៉ុមចេះតែរកទៅ
កាលពេលការពីដំបូងញ៉ុមមានចេះរកអី!!នឹកឃើញរកស៊ី សុខចិត្តដាច់ចិត្តខ្លួនឯងម៉ង
ដាច់ចិត្តថា ទោះម៉េចក៏ញ៉ុមខំប្រឹងរក ផ្លែសន្ទូចមានតែបួនទេណាស់អត់មានអីរកទេណាស់
ផ្លែសន្ទូចមានតែ៤ទេណាស់ដាក់បង្កៃត្រី ដាក់បង្កៃត្រីយូរៗបានផ្លែសន្ទូចច្រើនយកមកវាយ
ហើយដើរយប់ព្រលប់គ្មានខ្លាចពស់វែកអីទេនិយាយអោយត្រង់ ហើយគេថាមានខ្មោច
ញ៉ុមថាខ្មោចញ៉ុមដាក់ពីក្រោយញ៉ុមថាខ្មោចញ៉ុមស្គាល់តាំងពីជំនាន់អាពតហ្មំ!!គេថាទៅខាង
ណោះខ្មោចលង!! មែន!គេនិយាយ គេនិយាយគ្រប់គ្នា
គេខ្លាចខ្មោចគ្រប់គ្នាហាំ!!គេថាគេមិនហ៊ានទៅទេ
ញ៉ុមថាហេខ្មោចស្គាល់តាំងពីជំនាន់អាពតហ្មំ!!ដល់ពេលលឺញ៉ុមនិយយាអីចឹងគេក៏លែងនេះ
ទៅ
ញ៉ុមក៏ទៅតែលើភ្លឺតែប៉ុណ្ណឹងហិ!!លើភ្លឺប្រហែល៣តឹកហាំ!!ទៅដល់កាប់តែដើមត្នោតដាក់ពីលើ
អញ្ចឹងទៅ
អោយហ្មំយកគ្រឿងអាប្រដាប់ទាហានពីដើមហ្នឹងអាកៅស៊ូសំរាប់អាដល់ពេលយើងងាប់ហ្នឹង
គេរុំហ្នឹង អាហ្នឹងពេលហ្នឹងគេចែកអោយហើយតាំងពីបង់សង្គ្រោះបង់អីហ្នឹង
ទៅវែជំរុំមួយៗគេចែកអោយហើយ
ហើយញ៉ុមទុកសល់ប្រើលុះតែបានប្រពន្ធញ៉ុមហ្នឹងទល់តែ២ឆ្នាំហ្មំបានអស់
យកកៅស៊ូហ្នឹងក្រាលទៅចងមុងដេកលើភ្លឺហ្នឹង ជួនកាលដេកខាងនេះក៏ទឹកខាងនោះក៏ទឹក
អើយបើបំរ៉ាស់ទៅធ្លាក់ទឹកហើយ យប់ឡើងទៅមើលសន្ទូចទៅ
យូរៗបានចេះតែមានបានតិចតួចបានតិចតួចអញ្ចឹងទៅទិញសំណាញ់ទិញស្ពឺៗចេះតែរកទៅ
ញ៉ុមរៀនបំបែកខ្លួនឯងនឹកឃើញថាខ្លួនឯងវាកូនកំព្រាពីតូចមកបើយើងមិនតស៊ូវាអត់ហាំ!!!ញ៉ុ
មរៀនធ្វើជាងថ្នាក់ដល់ប្រពន្ធញ៉ុមខឹងរអ៊ូរទាំថាទៅធ្វើធ្វើស្អីបើយើងទៅធ្វើអត់ទាំងលុយអត់ទាំ
ងកាក់អីធ្វើមួយថ្ងៃៗញ៉ុមកពីវាយមងវិញញ៉ុមទៅធ្វើនឹងគេហើយរត់ជួយធ្វើគេហាំ!
មើលលិចមើលកើតជួនកាលគេហៅហូបបាយអីចឹងទៅស្រាផឹកអីបន្តិចបន្តួចអីចឹតងទៅណា
ស់!! បានហើយមកផ្ទះវិញមក ហើយដល់ពេលមកមើលធ្វើចាំទុកមើលគេធ្វើចាំទុក
មើលធ្វើចាំញ៉ុមចេះតែចាំទុកចាំទុកក្រោយមកញ៉ុមរៀនចេះធ្វើខ្លួនឯង
មិនត្រឹមតែប៉ុណ្ណឹងណាស់ ថ្នាក់ដល់យូរៗចេះធ្វើដល់ទូកង ទូកអីជាមួយគេដែរហ្នឹង ធ្វើកាណូត
កាណូតអា៧០តោនអីណោះ!!ក៏ញ៉ុមធ្វើកើតដែរ
ញ៉ុមចេះតែរៀនៗៗដល់ពេលញ៉ុមរៀមចេះទៅញ៉ុមលែងខ្វល់
ញ៉ុមរៀនញ៉ុមថាអាសំខាន់នៅលើគំរិះដែលយើងចេះ

តែយើងចេះហើយទៅណាក៏វាមិនចេះស្លាប់ដែរប៉ុន្តែគ្រាន់តែការងារយើងវាហាត់ វាខ្ញុំគេម៉េច ប៉ុន្តែគ្រាន់តែខ្ញុំគេដូចថាយើងធ្វើទូកធ្វើអី យើងខ្ញុំគេខ្ញុំម្នាក់ឯង បាទខ្ញុំតែម្ចាស់មួយទេណាស់!!

(មិត្ត)៖ អត់មានពីណាត្រួតលើ!!!

ខ៖  បាទអត់មានពីណាត្រួតពីលើ អញ្ចឹងបានញ៉ុមសុខចិត្ត ញ៉ុមថាមើលទៅរកតែចាប់ចំនុចមួយស្អីវាមិនបានចាប់ចំនុចអីមួយមិនបានញ៉ុមចាប់អាមុខរបររកត្រីហ្នឹងម្នាក់ឯងជូនកាលថ្ងៃណាញ៉ុមរករកទៅ ជូនកាលថ្ងៃណាញ៉ុមអត់អត់ទៅប៉ុន្តែគ្រាន់តែវាបានតែមួយហូប បានមួយហូបទាន់ទាន់មាត់គ្រាប់គ្រាន់។

កៈ
ទោះម៉េចក៏បានត្រីយកមកហូបដែរពូណោះទោះតែលក់មិនដាច់អីវ៉ាន់ណា!!ហ្នំ!!ត្រីញ៉ុមត្រីអត់ទេ ត្រីធម្មជាតិ មកដល់ផ្ទះមិនចង់ទាន់ផង បើថាត្រីត្រសក់ប៉ុណ្ណឹងៗៗៗ មួយ៧ ៨គីឡូហ្នំ!! ៤ ៥គីឡូ!!

កៈ  តែឥឡូវរកបានតែត្រីអីគេវិញពូ?

ខ៖  ប៉ុនពូរកកំផ្លៀញសិនហ្នំនៅខាងនោះតើ ខ្ចិលបង្វៀងទូកមកខាងនេះវិញម្យ៉ាងកូនចៅវានៅនេះវាច្រើនហា៎!!ខ្ចិលទៅណាទៅណីទៅ ប៉ុនដល់អញ្ចឹងបានពូនឹកឃើញថាពូចេះតែនឹកឃើញខុសម្យ៉ាងៗៗ នឹកឃើញខុសម្យ៉ាងខ្លួនឯងខុស ខុសម្យ៉ាងបើគិតទៅបើនិយាយអោយចំលោកពូខ្មាស់ ខ្មាស់នឹង ខ្មាស់ប្រធានសាខាមុនទៀតណោះ ខ្មាស់ អេង ប៊ុនហ៊្វចហ្នំ!!

កៈ  ម៉េចអញ្ចឹងវិញពូ?

ខ៖  ខ្មាស់ត្រឹមតែប៉ុននេះទេ អេង ប៊ុនហ៊្វចនិយាយល្អណាស់!!កៈ ចា៎!ខៈ ញ៉ុមនឹកឃើញប្រធានសាខាទោះបីជា!!

កៈ  គាត់សុទ្ធតែកូនប្រុស!!

ខ៖  ញ៉ុមធ្វើខុសប៉ុណ្ណឹងបានអីបានថាអោយអញ្ចេះអញ្ចុះមួយម៉ាត់អីអត់ នៅតែលួងលោមញ៉ុមអញ្ចឹង ថាពូអើយខ្ចិលខឹងមីង!! មុនដំបូងញ៉ុមគិតថារត់ចោលមីងតើ!!

ញុំមរត់ចោលមីងប្រហែល១០ថ្ងៃកន្លះខែ ដល់ពេលយូរៗញុំមបកមកវិញ
មកវិញទៅកន្លែងទៅវិហារសើច ញុំមថាហ៊ីពិបាកដៃរម្យ៉ាងដៃរបើនិយាយអាចំម៉ង
ឡើងដល់ស្តេចនៅជាន់ថ្មរអិល ទំរាំតែញុំមរាស្រ្តទៀត អញ្ចឹងបានថាថ្ងៃនេះញុំមខុស
ស្នែកឡើងញុំមគង់តែរកកន្លែងឃើញត្រូវវិញទេ!!

(មិត្ត)៖ និយាយប៉ុនហ្នឹចហ្នឹងពេលមុនធ្វើប្រធាននៅតាខ្មៅហ្នឹង?

ខ៖ ប្រធានសាខាយើង!!

ក៖ ហ្នឹងហើយយូរណាស់ហើយ!!

ខ៖ ញុំមមុនអេង ប៉ុនហ្នឹចទៀតហ្នំតាំងពីបងអី នេះធ្វើប្រធានសាខា
តាំងពីនៅជំនាន់អ៊ែលឌើរស្មិតហ្នំ!!

ក៖ យូរណាស់ហើយ!!

ខ៖ មិនមែន យ៉ូសែបស្មីធទេណាស់!!អ៊ែលឌើរស្មីតហ្នំ កាប់សិន!!

ក៖ អ៊ីចឹងពូមិញពូនិយាយមករំលងមកហួសសង្គ្រាមអស់រលីងហើយហ្នឹងឥឡូវនិយាយពីលន់
នល់ មុខមើលពូពូដឹងអីគេខ្លះពីជំនានន់លន់ នល់?

ខ៖ លន់ នល់ហេ?

ក៖ ចាំ!!

ខ៖ លន់ នល់បើនិយាយអ៊ីចឹងបើពូនិយាយទៅមហាសែនសប្បាយហើយ។

ក៖ ម៉េចវិញទៅ?

ខ៖ ពូទៅវាយសន្ធូច នុយជន្លេនហាំ!! ពូនិយាយប្រាប់ទៅចុះ
ថ្មើរហ្នឹងរត់ទៅវាយហើយយើងជិះទូកធម្មតា២នាក់បងហាំ!!ចុះម្តាយគាត់នៅកូនខ្ចី
កូនខ្ចីតូចប្រហែលចៅញុំមនៅប៉ុនមិញហ្នឹង
ប្រហាក់ប្រហែលជាខ្ទង់អត់ទាន់បានកន្លះខួបផងហ្នឹង។

កៈ ចាំ!!ប្រហែលជា៤ ៥ខែ ថានិយាយថាបាន៤ ៥ខែចុះ ទៅវាយសន្ទូចពីរនាក់តែបងទេ ហើយវាយសន្ទូចអត់មានច្រើនទេវាយតែ៣០០ផ្លែហ្នឹងពីរនាក់ ដោត២សារហ្នឹងសឹងទល់ភ្លឺហ្ន៎!!

កៈ ៣០០ផ្លែ?ខៈ បាទ!កៈ ច្រើនណាស់!!

ខៈ តែយើងអត់ចេះហាំ!!ហេអាខ្លះគេវាយដល់រាប់ពាន់ហ្ន៎!!

កៈ បានត្រីប៉ុន្មានទៅពូបានត្រីច្រើនខ្លាំងណាស់អីចឹង?

ខៈ ត្រីបានមកបានមួយកញ្ច្រែងមួយកញ្ច្រែងអ៊ិចឹងទៅ វាគ្រាន់តែយើងកំពុងតែវាយបណ្ដើរអីចឹងទៅទាហានចុះទៅទៅដល់រួចទៅគេទៅជួបជាមួយនឹងខ្មែរក្រហមទៅជួបជាមួយពួករំដោះហ្នឹង ។

កៈ ចាំ!!

ខៈ បាញ់គ្នាទៅយើងរត់ទៅ ហើយយើងនៅលើទូកហើយយើងអុំទូករត់ទៅណាស់ ពេលដែលអាដាកាតាយន្តហោះមកហាំ!! អាទំលាក់កង់មកមុនដំបូង មុនដំបូងដល់ពឹបឡើងបាញ់ពោង វាបាញ់ពោងទំលាក់ហាំ!!

កៈ ហ៊ឺ!!

ខៈ
បាញ់ពោងបន្តិចបានតិចអាដាកាតាមកដែរយប់ហាំ!!ភ្លើងវាទំលាក់មកឡើងភ្លឺពេញមេឃភ្លឺជាងថ្ងៃផង!!

(មិត្ត)ៈហ្នឹងហើយអាកប៉ាល់ហោះទំលាក់ភ្លើង!!

កៈ ហើយម៉េចទំលាក់ភ្លើង ឥឡូវមុនទំលាក់មកហ្នឹងគេដុតភ្លើងមកសិនពូហេ?វាប្រើអីរបស់វាដូចវាប្រើម៉ាញេទិចអីវា !!

កៈ ហ្ន៎!!

ខៈ គ្រាន់តែផោសមកពីលើភ្លឺឆត្រ័វាយោងទំលោះឆត្រ័ហ្ន៎!!

កៈ ហ្ន៎!!

ខ៖ ហ្នំឆត្រ័វាស្មើរតែមនុស្សយើងហ្នឹង!!

(មិត្ត)៖មីងអូតាថាភ្លើងឆេះកាល ទំលាក់ស្រុកញ៉ុមម្តងដែរនោះ!!

ខ៖
បាទ!!ហ៊ីស្រុកញ៉ុមមិនមែនតែម្តងទេតាំងពីឆ្នាំ៧០គត់(១៩៧០)ដល់តែឆ្នាំ៧៥(១៩៧៥)ហ្នឹង។

ក៖ ទំលាក់រហូត?

ខ៖
បាទ!!វាបាញ់អញ្ចឹងទៅដល់ពេលពេលទំលាក់អញ្ចឹងភ្លើងភ្លឺចែសអ៊ឺចឹងទៅ!!ញ៉ុមថាហ្នំដល់ហើយគ្រាន់តែឃើញអាទំលាក់កង់មកវាបាញ់យកពង្ស
វាបាញ់យកពង្សហាំ!!ពង្សរបស់វាផ្សែងសរអណ្តែតឡើងទៅលើប្រហែល២០ ៣០ម៉ែត្រ
ទោះបីយើងដាក់បង្កប់អីក៏អត់បាត់ដែរ ជាពិសេសញ៉ុមជាមួយបងញ៉ុម៦ ៧នាក់ហាំ!!
វាបាញ់ទំលាក់អាក្បាលក្រោយអានេះរបស់វាហ្នឹងតែប៉ុណ្ណឹងទេពង្សវាហ្នឹងអាផ្សែងពង្សហ្នឹងហាំ!នាំគ្នាយកអាផ្សែងពង្សវាហ្នឹងយកទៅកប់ដាក់ជាន់ភក់ម៉េចក៏វាអត់បាត់ដែរ
នៅតែចេញផ្សែងមក បានតែមួយភ្លេតយន្តហោះមកបាញ់ទំលាក់ហើយ
អាហ្នឹងដល់អញ្ចឹងមនុស្សចេះតែហ៊ានទៅហ៊ានទៅហាំ!!
ដល់តែពេលកំពុងដោតសន្ទូងដោតដោតៗលែងមកតែម្តង
គ្រាន់តែមកពឹបទំលាក់សន្ទូចចុះរត់ ទឹមតែដោតប្រហែលបានតែ២០០ផ្លែអីអញ្ចឹងណាស់
រត់អ៊ុំទូកចូលក្នុងព្រៃ
ចូលក្នុងព្រៃដល់ចូលក្នុងព្រៃចូលរួចពន្លិចទូកខោអាវកុំថាទទឹកមិនទទឹកអីរងាខែរងាអីខែកក្តិកអីទៅតែទាំងអស់ហ្នឹង ពន្លិចហ្អែងចោលទៅ។

ក៖ ធ្វើម៉េចអោយរួចខ្លួនសិន។

ខ៖ ពន្លិចទូកផ្កាប ផ្កាបទូកហាំ!!
ផ្កាបហើយញាត់អាក្រោមឈើរៀមហាំ!!នៅស្រុកញ៉ុមគេព្រៃលិចទឹកនោះ!!

ក៖ ចាំ!!

ខ៖ ញ៉ាត់ចោលទៅនាំគ្នាហែលហែល ចេញទៅ
ហើយកុំអោយរលកទឹកពេកវាមើលពីលើមកឃើញហាំ!!

អាដាកាតាហ្នឹងវានៅតែពីលើក្បាលហ្នឹង លឹម លឹមៗៗធ្វើតិចៗៗកុំអោយវារលកទឹកហ្នឹង វាបាញ់ថាហ្ងំ វាបាញ់ភ្លើងវាដូចខ្សែករអញ្ចឹង គ្រាប់ហាំ!

កៈ ហ៊ឺ!!

ខៈ ខ្សែករមាសមិនស្មើផង
វាលាន់មកពីលើឈ្វាកៗៗៗៗអោយតែស្លាប់នៅក្នុងទឹកនេះជឺបៗៗៗៗៗៗបើថាចំវិញដំរីក៏វាងាប់ដែរ បើបាញ់សុទ្ធតែមីហ្គៀលហើយហ្នឹង បាញ់សុទ្ធតែដុសសេត អាដុសសេត ១២ មីតាយើរបានហ្វែងមកពីលើ ហ្វែងសុទ្ធតែរបស់អាគាំងទាំងអស់!! ញ៉ុមនឹកឃើញថាងាប់ហើយ វាបើថាកាលពីជំនាន់នោះគ្មានអ្នកណាគេចរួចទេបើគិតទៅមួយជូរស្រុកញ៉ុមវាអញ្ចឹងទាំងអស់ហ្នឹង វាសុទ្ធតែមនុស្សរស់ពីខ្មោចហាំ!!និយាយចំអញ្ចេះ ។

កៈ សុទ្ធតែវេទនាដល់ករហើយពូ!!

ខៈ បាទ!!ដល់តែពេល!!

កៈ ទំលាក់មករណ្ដៅប៉ុនៗម៉ាន់ទៅពូ?

ខៈ រណ្ដៅវា?

កៈ ចាំអាគ្រាប់ធំៗអីវ៉ាន់ហ្នឹងហ្ងំ!!

ខៈ អាគ្រាប់បូមហ្នឹងហេ?

កៈ ចាំ!!

ខៈ ហេរណ្ដៅវា វាយើងនិយាយទៅវាប្រហាក់ប្រហែលជាខ្ទង់១០ម៉ែត្រអី ១០ម៉ែត្របួនជ្រុង។

កៈ ហ៊ឺៗ!!

ខៈ ជំរៅចូល១៥ម៉ែត្រហាំ!!

កៈ អូយ!!

ខៈ ជំរៅចូលក្រោមហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ ហើយអំបែងរបស់វាប៉ុនៗកណ្ដៀវ ហ្ន៎ត្រូវមាំងអាខ្លះដួនកាលដាច់ជា២ហ្ន៎!!

ក៖ អើយ!!

ខ៖ បើគិតទៅ មួយថ្ងៃណាដែលថាអត់មនុស្សងាប់ទេជំនាន់ហ្នឹងហ្ន៎!!បើយើងនិយាយទៅ។ក៖ចាំ!!ខ៖ ប៉ុនតែស្រុកគាត់ហ្នឹងញ៉ុមអត់ដឹងទេណាស់
បើគាត់ឮថាគាត់នៅភ្នំពេញអ្នកនៅភ្នំពេញរួចហើយ។

(មិត្ត)៖កាលលន់ នល់ហ្នឹងនៅបាទី!!

ខ៖ នៅបាទីហេ?

(មិត្ត)៖ ចាំ!!បាទីខេត្តតាកែវហាំ!!

ខ៖ ហ្ន៎អ៊ីចឹងខាងតំបន់រំដោះហ្នឹង គាត់នៅខាងរំដោះបាត់ហើយហ្នឹង!!

(មិត្ត)៖ហ្នឹង!!

ខ៖ ញ៉ុមនេះអត់ទេ។

ក៖ រហូតម៉ងហេពូហេទំលាក់?

ខ៖ ចំបក់ញ៉ុមនៅខាងលន់ នល់ នៅលន់ នល់
ដល់ពេលញ៉ុមខឹងបានគេសម្លាប់ឪពុកទៅបានញ៉ុមទៅខាងរំដោះវិញហ្នឹង។

ក៖ ទំលាក់ឪពុកហេ?

ខ៖ ចុះឪពុកញ៉ុមមិនគេសម្លាប់ចោលនៅទន្លេបួនមុខ ដែលញ៉ុមនិយាយពេលមុនហ្នឹង!!

ក៖ អញ្ចឹងពូ ពេលចូលខាងរំដោះហ្នឹងអាយុក្មេងដែរហ្នឹងអញ្ចឹង?

ខ៖
ខាងរំដោះឆ្នាំ៧០(១៩៧០)គត់ហាំយើងគិតមើលទៅឆ្នាំ៧០(១៩៧០)គត់ញ៉ុមអាយុបាន១០ឆ្នាំហើយ!!

កៈ ចាំ!!

ខៈ បាទដល់ពេលបានមក៧៥(១៩៧៥)ញ៉ុមបាន១៥។កៈ ចាំ!!ខៈ  មក៧៩(១៩៧៩)បាន១៩។

កៈ ចាំ!!

ខៈ ញ៉ុមកើតឆ្នាំ៧០(១៩៧០)ហ្នឹង។អញ្ចឹងគាត់កើតឆ្នាំប្រហែល៥៨(១៩៥៨)
(និយាយពីមិត្តគាត់កើតឆ្នាំ១៩៥៨)។

កៈ ហ្នឹងហើយម៉ែកើត៥៨(១៩៥៨) ហើយពូដល់ពេលចប់ពីអាលន់ នល់ហ្នឹងមកទៅ!!

ខៈ  អញ្ចឹងគាត់ឆ្នាំជ្រូក!!ឆ្នាំកុល?

(មិត្រ)ៈ អត់ទេញ៉ុមឆ្នាំច!!

ខៈ ច?

(មិត្ត)ៈចាំ!!

ខៈ  ហោមិនមែនទេ!!ចតាំងពី បើនិយាយទៅ៥៩ហើយ!!

កៈ  បើនិយាយទៅពូឆ្នាំខ្មែរវាមាន២ (ចូលឆ្នាំខ្មែរវាមានឆ្នាំបារាំងពីរជាប់គ្នាសំរាប់ឆ្នាំខែរ)។

(មិត្ត)ៈ ៥៩ ៦០ ៦០ហើយ!!

កៈ  អ៊ីចឹងពូដល់ពេលចប់លន់ នល់ មកដល់ពេលចូលប៉ុល  ពតវិញម្តង
តើជីវិតពូនឹងក្រុមគ្រួសារពូម៉េចខ្លះពូរៀបរាប់មើល?

ខៈ  មានក្រុមគ្រួសារអីទៀតមានតែម្នាក់ឯងហ្នឹង
និយាយអ៊ីចឹងពេលពួកគាត់ស្លាប់មុននឹងពួកគាត់ស្លាប់ ពូចូលជាមួយគ្នាសិនបានស្លាប់មែនទេ?

ខៈ  អត់ដឹង អត់ដឹងទាំងអស់បែកគ្នាតាំងពីឆ្នាំ៧៥(១៩៧៥)!!!

កៈ ហ្ហ៎!!

ខៈ  វាបំបែកគ្នាទាំងអស់ម៉ង!!

ក៖  តែពូម៉េចដឹងថាបងប្អូនពូស្លាប់ទាំងអស់ហើមវិញដោយសារគេប្រាប់ឬក៏អី?

ខ៖  គេអ្នកនៅញាតិជិតខាងគេប្រាប់។

ក៖  គេថាម៉េចខ្លះពូ?

ខ៖  គេថាដូចថាមួយគ្រួសារហ្នឹងសុទ្ធតែបងប្អូនគេប្រាប់ដែរហ្នឹង។

ក៖ ចាំ!!

ខ៖  គេថាគាត់ស្លាប់ហើមដោយសារអត់បាយ ហើយបងនោះគាត់ធ្វើការ
គាត់ធ្វើការហួសកំលាំង ធ្វើ ចុះពីដើមគ្រាន់តែយើងយោងទឹកបាចដាក់សណ្ឋាប់ហ្នឹងក្នុងម្នាក់
យើងសំរាកម្តងក្នុងម្នាក់យ៉ាងតិចក៏៧០០យ៉ោងដែរឬមួយទៅ១០០០យោងបានឈប់ម្តង។

ក៖ ហ៊ឺៗ!!

ខ៖  ១០០០យោងមនុស្សយើងចុះវាអត់បាយផង វាគ្មានថ្នាំគ្មានសង្កូវទៀត
ថ្នាំជំនាន់នោះសុទ្ធតែថ្នាំអាចមន៍ទន្សាយហ្នឹង!!សុទ្ធតែថ្នាំអាចមន៍ទន្សាយហ្នឹងជំានន់នោះមាន
ថ្នាំអីនឹងផឹក ។

ក៖  អើយអ៊ីចឹងអត់មានថ្នាំអីផ្សេងតែម្តង?

ខ៖  និយាយ និយាយមានថ្នាំអីកាលពីជំនាន់ហ្នឹង មានតែអាដើមជំឡូងធ្វើថ្នាំក្រពះហ្នឹង
ដើមជំឡូងគេដុះហើយគេដាក់លាយជាមួយស្ករទឹកឃ្មុំហ្នឹងតិចតួចទៅផ្អែមៗសុំគេហាំ!!យើង
បើថាពេលរួចទៅ !! មុនដំបូងនៅស្រុកខ្ញុំ
ហានៅភូមិខ្ញុំហ្នឹងហាំ!!មួយកំប៉ុងពីរនាក់ផុតតែពីរមួយកំប៉ុងពីរនាក់មួយកំប៉ុងបួន
បួនឡើងដល់ប្រាំបី ពីប្រាំបីឡើងដល់មួយកំប៉ុង៥០នាក់៣០០នាក់ មួយការដ្ឋាន
គិតមើលទៅទៅប៉ុន្នានកំប៉ុង បបរ ដាច់ពីបបរទៅនៅសល់គ្រាប់ពោតនៅ១២គ្រាប់
ទៅលេងសើចអីមួយពេល។

ក៖  ពូនៅដល់ណាគេបំបែកគេជំលៀសនៅដល់ណាវិញពេលប៉ុល ពត?

ខ៖  ប៉ុល ពត ប្រាសាទ!!

ក៖ នៅប្រាសាទ?

ខ៖ នៅខេត្តពោធិ៍សាត់។

ក៖ នៅពោធិ៍សាត់ហេ?

ខ៖ បាទ!!

ក៖ កន្លែងគេសម្លាប់សាហាវហោព្ធនៅហ្នឹង?

ខ៖ ហ៊ឺ!!កន្លែងហ្នឹងទូស្លែងអត់ស្មើនឹងគ្រាចក្រោលផងបឹងគុលរុញចូលក្នុងនេះតើ រុញចូលឡ អាឡដុតឥដ្ឋយើងហ្នឹង ឡដុតក្បឿង ៣០០នាក់អីហ្នឹងដាក់ចូលតំរៀបជួរដុត ចាក់សោរជាប់ហ្នឹងហើយវាដុតតើ!!!

ក៖ ចំដុតមនុស្សទាំងរស់!!

ខ៖ ហ៊ឺ!!តែវាបិតជិតហើយលាន់លឺសូត្ររង្វងដូចឃ្មុំអញ្ចឹង។

ក៖ ចាំ!!

ខ៖ ចាំទៅ មុននឹងវាសម្លាប់វាចាក់មីក្រូឡើងត្រហឹងហ្ហ៉!!មុននឹងដុតហា!!ទោះយើងលឺក៏មិនដឹងធ្វើស្អីវាធ្វើអីឈ្មោះវាព្រោះអីវាយកទៅនៅកណ្ដាលបឹង គ្រាចក្រោល អើរបើគិតទៅនៅវាលចម្ងាយរ៉ាប់គីឡូពីភូមិហ្នឹង!!

(មិត្ត)៖ គេនិយាយគន្ធា គេបញ្ចូលក្នុងឡហ្នឹង។

ក៖ ហើយដុតម៉ង?

ខ៖ បាទ!!

(មិត្ត)៖ ដុតទាំងរស់។

ខ៖ តែឥឡូវគេយកធ្វើវត្តតើ!! វត្តគ្រាចក្រោលហ្នឹង!!

ក៖ អាក្រក់ម្ល៉េះព្ធអើយ!!

ខ៖  អីចឹងបានអំនោះហៅធ្វើបុណ្យធ្វើអីហែរកន្ទេលហែរអីទៅគិតទៅ៦
៧ឆ្នាំហើយគាត់ហៅញ៉ុមតើ!!ញ៉ុមអត់ដែលបានទៅទេ!!គាត់ថាទៅទៅជាមួយគាត់ទៅ
ទៅជាមួយគាត់ទៅទៅធ្វើបុណ្យជាមួយគាត់ទៅទៅពុកម្ដាយនៅឯណោះទៅនាំគ្នាទៅឧទ្ទិស
ស្ពានឧទ្ទិសអីទៅណាស់!!ដល់ពេលញ៉ុមអត់ទៅ៦ ៧ឆ្នាំគាត់ថាអោយញ៉ុម
គាត់ថាអើយទៅហៅអីគេគេ គេពួកយេស៊ូវគេថាអោយញ៉ុមអញ្ចឹង គេថាអោយញ៉ុមអញ្ចឹង។

ក៖ ចាំ!!

ខ៖ ញ៉ុមថាចុះយេស៊ូវអត់ចេះធ្វើបុណ្យ?ញ៉ុមនិយាយអីចឹងទៅវិញទៅ!!

ក៖ ចាំ!!

ខ៖ ញ៉ុមអត់មានពាក្យអីឆ្លើយនឹងគេញ៉ុមអត់មានពាក្យអីឆ្លើងថាអញ្ចឹងហើយ!
គ្រាន់តែធ្វើបុណ្យហែរកន្ទេលហែរអីទៅហ្នឹង!!

ក៖ ចាំ!!ពូនិយាយប្រាប់ហ្វូថាពេលបងប្អូនស្លាប់ទៅពូចូលធ្វើឆ្លបម៉េចទៅពូ?ម៉េចវិញទៅ?

ខ៖
មុនដំបូងពូចូលធ្វើឆ្លបហ្នឹងអត់ទាន់នេះទេបងប្អូនអត់ទាន់ដឹងថាបងប្អូនហ្នឹងស្លាប់ទេអាហ្នឹងអា
ហ្នឹងឆ្នាំ៧៧(១៩៧៧)ទេ។ក៖ ហ្វំ!!ខ៖  ឆ្នាំ៧៧(១៩៧៧)គេអោយពូធ្វើឆ្លប។ក៖ ហ្វ!!ខ៖
ធ្វើឆ្លបធ្វើនិនាសារគេទៀត។

ក៖ ចាំ!!

ខ៖  ដល់តែធ្វើនិន្ទាសារគេ!!

ក៖  ពូម៉េចសំរេចចិត្តចូលទៅធ្វើឆ្លបវិញ?

ខ៖  អង្គការដាក់ទោសហាំ!!

ក៖ គេហៅទៅតែម្ដងពូហេ?

ខ៖  ហ្នឹងហើយអង្គការគេអោយធ្វើ។

ក៖  បើអត់ធ្វើគឺស្លាប់?

ខ៖  បើអត់ធ្វើស្លាប់ មានសង្ឃឹមអីនឹងរស់ទៀត!! បើ បើសម្លាប់មនុស្សដូចសម្លាប់អីអីចឹងហ្នឹង!!

ក៖  ចាំ!!ហើយអីចឹងម៉េចវិញទៅពូ?

ខ៖  ព្រោះ ដល់ពេលអញ្ចឹងគេហៅពូទៅធ្វើឆ្លបធ្វើទៅធ្វើទៅ
ទៅដល់គេអោយពូឃ្វាលគោគេអោយពូរត់សំបុត្រ
ហើយគ្រាន់តែមីសេះរបស់គេតាំងពីមីកប៉ាល់ភ្លើង ហ្វាំឈ្មោះសេះគេពិរោះណាស់
មើលអាមករា អាស្វាត អាស្វាយចេក មីចិញ្រ្ចាំប្រហុក មីកប៉ាល់ភ្លើង
សុទ្ធតែសេះជាប់ចំណាត់ថ្នាក់ហើយញ៉ុមប្រាប់ សេះមួយខេត្តពោធិ៍សាត់ហ្នឹង
លឿនចោលម្រាយហើយញ៉ុមប្រាប់ទៅ ឆ្លងកាត់ស្រុកហាំ ជិះហាំ!!

ក៖ហ៊ី!!

ខ៖  ញ៉ុមជិះពីផ្ដែកង្កែបមក មកដល់ស្រុកខ្ពាន ខ្វង់ប្រហាក់ប្រហែល៨ម៉ោងទេតាមមើល!!

ក៖  ពូជិះអីគេវិញជិះសេះហ្នឹងហោ?

ខ៖  សេះហ្នឹង។

ក៖  យកសារអោយគេពូហោ?

ខ៖  ចុះយើងរត់ពីកន្លែងមួយទៅកន្លែងមួយ មានតែប៉ុណ្ណឹង ដល់ពេលយើងចេះតែធ្វើទៅធ្វើ
យើងយកចិត្តអោយគេម៉េច យើងមើលគោអោយគេសូម្បីតែរទេះគេហ្នឹង!!

ក៖ ចាំ!!

ខ៖ ក៏រ៉ៃដាក់សូក្រំអោយគេអោយស្អាតដែរ!!

ក៖ ចាំ!!

ខ៖  ហើយអាសូក្រំ សុទ្ធតែអាសូក្រំនេះគេប៉ុនតែគ្រាន់តែថាចង្កៀងគេ
អើយចង្កៀងគេសុទ្ធតែត្បូងហើយនឹងមាស
ត្បូងហើយនឹងមាសមិនដឹងយកទៅប៉ារ៉ែនអីគេទេ!!

ក៖  ពេលហ្នឹងគេលែងចាយលែងអីហើយអស់ហើយពូណោះ?

ខ៖ មាសមួយដំឡឹងដូរប្រហុកអត់បានមួយចង្វាផងហ្នឹង
មានពីណាគេចាយមាសហ្នឹងគេយកធ្វើស្អី!!

ក៖ ចាំ!!គេទុកចោលម៉ងពូណោះ?

ខ៖ នៅមួយហឹកហ្នឹងពូនៅក្មេងតែបើសិនជាពូចាស់អីដូចឥឡូវវិញងាប់ហើយ។

ក៖ យកទុកពូហោ?

ខ៖ នៅក្មេងមាស២ផ្តិលខាត់ប៉ុននេះ គេអោយពុយកទុក
ពូយកទៅដល់បោះលើរទេះអោយគេទៅញុំមទុក ញុំមទុកអោយគេទេណាស់អាហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖ មានដឹងថាមាសហ្នឹង មានដឹងថាចាយអីអត់ដឹងទេ ហើយម្យ៉ាងពូក៏មិនដឹងថាខ្លួនពូរស់ដែរ!!

ក៖ ហ្ហ៎!!

ខ៖ បើយើងជាប់ពេញកន្តាប់ដៃអស់លោកនោះហើយអញ្ចឹងហ្នឹង។

ក៖
ពូធ្វើឆ្លបហ្នឹងក្រៅពីរត់សំបុត្រគេមានដែលអោយពូចាត់មនុស្សទៅសម្លាប់អ្នកណាគេអីអត់?

ខ៖ អត់ទេអត់ទេៗៗៗ!!!

ក៖ ចាំ!!

ខ៖ អត់ទេ!!

ក៖ មានអាភ្នាក់ងារផ្សេងទៀតហោ?

ខ៖ បើមើលគោមាន!!ហេភ្នាក់ងារគេអ្នកសម្លាប់ គេអ្នកសម្លាប់ផ្សេងតើ!!

ក៖ ពូមានដែលមានពួកម៉ាក់ជាអាអ្នកហ្នឹងទេ?

ខ៖ បាទ??

កៈ ជាអាអ្នកដែលសម្លាប់គេហ្នឹងអត់?ពួកម៉ាក់ដែលធ្វើឆ្លបជាមួយគ្នាអីអញ្ចឹងទៅណាស់?

ខៈ អត់!! គេវា
ពួកវាពួកអាអស់ហ្នឹងវាមិនដែលអោយពួកយើងជួបមុខទេពួកអ្នកធ្វើអញ្ចឹងៗហ្នំ!!
ម្យ៉ាងក៏ពួកវាមិនអោយយើងស្គាល់មុខពួកវាដែរហ្នំ!!

កៈ ខ្លាចសងសឹងថ្ងៃក្រោយហាំ!!

ខៈ
វាពិបាកអញ្ចឹងណាស់!!វាបើកាលណាយើងស្គាល់មុខវាច្បាស់ទៅខ្លាចក្រែងលោថ្ងៃក្រោយទៅ
ហ្នំអ្នកនេះខ្សែស្រលាយអ្នកនេះ អ្នកនេះខ្សែស្រលាយអ្នកនេះ
តែមានបញ្ហាអីទៅក្រែងលោវាពិបាក ហើយឆ្នាំ៧៧(១៩៧៧)យួនវ៉ៃពីកើតនេះទៀតទៅ
គេប្រុងដកពូយកទៅវ៉ៃនៅព្រំដែនទៀតហ្នំ!!ប៉ុន្តែពូអត់
បានគេជួយពួកអ្នកធំៗគេចេះជួយពូរហូត។

កៈ ចាំ!!

ខៈ ថាមិនបាច់ទៅទេ បើសិនជាទៅក៏ពូងាប់ដែរ ពួកអាមេរិចបាញ់ពូងាប់ដែរ។

កៈ តែពូធ្វើឆ្លបបានប៉ុន្មានឆ្នាំបានឈប់ធ្វើវិញ?

ខៈ ធ្វើបានប្រហែលជាមួយឆ្នាំកន្លះ។

កៈ វាដោះលែង លែងដោយសារបែកបានឈប់ធ្វើ!!

ខៈ គេរាយការណ៍គេថាពូពួកអ្នកនេះពួកនាយទុន ។

កៈ ហ៊ឺ!!

ខៈ មកដឹងត្រឹមប៉ុណ្ណឹងបិសតែងាប់!

កៈ ហើយពូទៅណាបានរួចខ្លួនវិញ?

ខៈ អត់រត់ទេគេអោយដើរតាមកងចល័ត !!

កៈ ហ្ហ៎!!

ខៈ ដល់ពេលពូនៅកងចល័តស្រុកយូរៗៗទៅនៅកងរទេះ
គេឃើញពូជាអ្នកប៉ុនថៃគោបានល្អ ពូថៃគោធាត់ៗណាស់ ។

កៈ ចា៎!!

ខៈ ប៉ុនថៃគោដល់ពេលចេះតែអោយពូហ្នឹង ចេះតែគេយកចិត្តទុកដាក់ជាមួយពូ
គេអោយពូគេអោយពូហ្នឹងធ្វើការអីក៏ដោយពូធ្វើការអីក៏ដោយអោយតែពូចាប់ផ្ដើមភ្លែតឡើង
អោយយោបល់ទៅមើលគោ ស្រាប់តែគោគេប្រគល់អោយប៉ុន្មានក្រោលហ្ហ៎ ៣ក្រោហ្នឹង
ចូលជាង១០០០ក្បាល។

កៈ ចំ !!ហើយអោយពូទៅមើលតែម្នាក់ឯង?គ្នាប៉ុន្មាននាក់ទៅ?

ខៈ
ចុះនៅស្រុកហ្នឹងមានអីយើងមើលតែម្នាក់ឯងក៏វាមិនស្អីដែរ!!ប៉ុន្តែអោយតែបានទៅនៅកន្លែង
ហ្នឹងរស់ទៅ ចុះគោគ្រាន់តែព្រឹកឡើងប្រលែងចេញអស់ទៅ
ល្ងាចឡើងវាដើរបញ្ចូលក្រោលខ្លួនឯងវិញតើ!!

កៈ វាចូលមកខ្លួនវាអិចឹងទៅ?

ខៈ ហ្នឹងហើយ មើលវាមិនមែនមើលតែម្នាក់ឯងទេ!!មើល៣
៥នាក់ហ្ហ៎!!ប៉ុន្តែគ្រាន់តែយើងមើលម្នាក់ឯងក៏គ្មានស្អីដែរ!!
យើងមានទៅច្រូតស្មៅច្រូតអីអោយវាស៊ី ។

កៈ ស៊ីខ្លួនវា!!

ខៈ ដល់ពេលគោងាប់គោអីយើងរាយការប្រាប់គេ យើងវាត្រង់ហា៎!!

កៈ ចា៎!!

ខៈ អ្នកនៅមុនៗគេយកទៅវ៉ៃចោលព្រោះតែអារឿងគោងាប់គោអីអញ្ចឹងទៅ
ទៅលួចយកទៅដុតយកទៅអាំងយកទៅអីអញ្ចឹងគេដឹងហា៎!!

កៈ ហ្ហ៎!!

ខៈ  យកទៅវ៉ៃចោល
យកទៅវ៉ៃទាំងពូជទាំងពូជហ្ហ៎!!មិនមែនទៅសម្លាប់ស្លាប់តែខ្លួនហើយឯណា!!

កៈ ចា៎!!

ខៈ ស្រាវជ្រាវប្រវត្តិទៅ ណោះបងបងប្អូននៅនឹងស្រុកភូមិនេះ
ម៉ែឪបងប្អូនកូនចៅបងប្អូនកូនក្មួយ សម្លាប់ចោលទាំងអស់វាអត់ទុកទេ
វាថាបើយើងខុសតែមួយវ៉ៃតែមួយអីឯណា!!

កៈ ទាំងខ្សែ!!

ខៈ ទាំងខ្សែ!!

កៈ  គេថាជីកស្មៅជីកទាំងឬសហ្នឹងពូហេ?

ខៈ  ហ្នឹងហើយ ម៉ាជីដូន ម៉ាបងប្អូនជីដូនមួយបង្កើតហ្នឹងទៅតែទាំងអស់ហ្នឹង មានស្អី!!

កៈ  អញ្ចឹងពូពេលអាថ្ងៃចុងក្រោយពេលដែលយួនចូលមកនោះម៉េចវិញទៅពូ យួនចូលមក?

ខៈ  យួនចូលមកពូរត់ចូល រត់ចូលមកខ្មែរក្រហម ហ្វើយរត់ចូលទៅខាងចោរព្រៃ ។

កៈ ចា៎!!

ខៈ រត់ចូលទៅខាងចោរព្រៃដូចពូថាចងខ្សែតីក្រហមហ្នឹង។

កៈ ចា៎!!

ខៈ  អាហ្នឹងអ៊ីចឹង!!

កៈ  តែពេលហ្នឹងអាហ្នឹងពូធ្វើ ចូលខាងខ្មែរក្រហម?

ខៈ  ចូលខ្មែរក្រហម ចូលខាងចោរព្រៃមុន!!

កៈ ខ្មែរក្រហមខាងប៉ុល ពតមែនទេពូ?

ខ៖ បាទ!!ចូលទៅខាងហ្នឹងមុន!!

ក៖ ហើយម៉េចចូលទៅខាងហ្នឹងមុន តែចូលទៅខាងហ្នឹងដឹងតែគេសត្រូវជាមួយគ្នាហើយ?

ខ៖ ចូលពេលទៅជំរុំ ។

ក៖ ហ្ន៎!!

ខ៖ ទៅថៃហ្ន៎!!

ក៖ ហ្នឹងហើយហើយពូប្រាប់ថាអត់មានអីពិបាកទៀតណាអត់តែលគោលម្នាក់ឯងទៀត!!

ខ៖ ម្នាក់ឯងទៅគិតគូរអី!!

ក៖ ពេលណាពេលលហ្នឹងទៅពូហោ?

ខ៖ តែពេលណាពេលហ្នឹងហើយ!!

ក៖ ពេលណាពេលហ្នឹង
អ៊ីចឹងពូចប់សង្គ្រាមអីអស់ហើយដល់ពេលអ៊ិចឹងបានដើរអីអញ្ចឹងដូចពូបានរៀបរាប់មកអញ្ចឹង
អូខេឥឡូវនៅមួយទៀតឥឡូវចូលដល់កូនតែម្តង
រៀបការហើយជាមួយមីងមកមានកូនប៉ុន្មាននាក់ដែរពូ?

ខ៖ ៦។

ក៖ ៦នាក់ហោ?

ខ៖ ស្រី៣ប្រុស៣។

ក៖ ពូរៀបរាប់ឈ្មោះពួកគាត់ទាំងអស់មើល!!

ខ៖ វិបុល ស្រីមុំ!!

ក៖ បន្ទាប់ទៀត?

ខ៖ វិបុល ស្រីមុំ វិបុល និមល វិបុល បូរី វិបុល សម្តស្ស វិបុល បូរ៉ា វិបុល បុរី!!

កៈ  ចាំហ្នឹងហើយអ៊ីចឹង នៅក្នុងបន្ទុកគ្រួសារកូនស្រីរបស់លោកពូឈ្មោះវិបុល ស្រីមុំ
ដូចបានអានប្រាប់ពីប្រពន្ធដែរគឺកូនគាត់ស្រីមុំ គឺកើតនៅក្នុងថ្ងៃ០៣ ខែ០១ ឆ្នាំ១៩៨៥ និមល
កើតនៅថ្ងៃ០៧ ខែ០៧ ៩០(១៩៩០)បូរីកើតនៅក្នុងថ្ងៃ០៩ ខែ០៥ ឆ្នាំ១៩៩៣
សម្ផស្សកើតនៅក្នុងថ្ងៃទី១០ខែ១១ឆ្នាំ១៩៩៦ បូរ៉ាកើតនៅក្នុងថ្ងៃទី០៩ខែ០៤ឆ្នាំ១៩៩៩
នឹងបូរ៉ុកើតនៅក្នុងឆ្នាំ២០០២ថ្ងៃទី០១ ខែ១១
អ៊ីចឹងពូសំរាប់កូនទាំងអស់ពូអោយកូនទៅរៀនទាំងអស់គ្នាមែនតើពូហោ?

ខៈ  រៀន!!

កៈ ចាំ!!

ខៈ  ប៉ុន្តែវារៀនវាមិនចេះផង វារៀនអាយើងរៀនវាខ្វះមុខខ្វះក្រោយ
ទៅរៀនអញ្ជឹងទៅដល់ពេលអាឪពុកម្តាយអត់អញ្ជឹងខ្វះខាតអញ្ជឹងទៅនាំគ្នាមកបេះត្រកួនបេះ
អីអញ្ជឹងទៅព្រឹកឡើងបានលុយទៅរៀនខ្លះអញ្ជឹងទៅ។

កៈ ចាំ!!តែឥឡូវគ្រាន់បើហើយពូហី?

ខៈ  ម៉ែឪនេះរកអង្ករកស្រូវអីអ៊ីចឹងទុកគ្រាន់ផ្ចុកអោយកូន ក្តារ
សៀវភៅអីអញ្ជឹងទៅ!!ហើយអាកូនលុយទៅរៀនជូនកាលវានាំគ្នាទៅបេះត្រកួនទៅបេះព្រលិ
តអីអ៊ីចឹងទៅ។

កៈ ចាំ!!

ខៈ អើយជីវភាពពូពិបាកនិយាយណាស់!!និយាយនាំតែនិយាយពិបាកណាពីមុនមក
ប៉ុន្តែមកឥឡូវមកពូវារៀងលំបាកដែរតែគ្រាន់តែលំបាកមធ្យមវាមិន។

កៈ  គ្រាន់បើហើយពូណោះ?

ខៈ  បាទបាទ!!

កៈ
អញ្ជឹងពូមួយនេះគឺជាសំនួរមួយចុងក្រោយតើពូមានពាក្យពេចន៍អីគេខ្លះដែលពូចង់ផ្តែផ្តាំកូន
ចៅជំនាន់ក្រោយអោយគាត់ដើរលើផ្លូវម៉េចដែរ ហើយក៏ដូចជាមានក្តីសង្ឃឹមម៉េចដែរ?

ខ៖ ហ្នឹកូនចៅពូ ពូគ្រាន់តែនិយាយអញ្ចេះទេ
និយាយអោយចំម៉ងគ្រាន់តែថាអារឿងកូនចៅកុំយកសំដីគេខ្លាំងពេកយកសំដីឪពុកម្តាយខ្លះ
បើយកសំដីខាងគេខ្លាំងពេកតែស្រួលមិនស្រួលខ្លាចតែអាចូលថ្លុង ខ្លាចតែអាជក់ម៉ាជក់អីហ្នឹង
ពូភ័យណាស់ រាល់ថ្ងៃហ្នឹង ។

ក៖ ចាំ!!

ខ៖ ព្រោះអីមើលទៅវាពេញអស់ហើយហ្នឹង វាពេញស្រុកពេញប្រទេសអីហើយអស់ហ្នឹង
នៅសល់តែកូនពូអាមួយក្តាប់ទូចហ្នឹងហ៎!!

ក៖ ពូមើលអោយបានពូ!!

ខ៖ ទាល់តែអីចឹងបានថាតែម៉េចម៉ាពូមិនរ៉ៃទេរំពាត់
ប៉ុន្តែគ្រាន់តែសំដីរបស់ពូគ្រាន់តែដាក់អោយតែមួយម៉ាត់ៗ។

ក៖ ចុកចាប់ម៉ង!!

ខ៖ បាទ!!គ្រានតែថាពូរកស៊ីហាត់ណាស់មិនមែនរកទុកទេ រកអោយកូនស៊ី ។

ក៖ ចាំ!!

ខ៖ ហាត់មែនទែនណាស់!!

ក៖ ចាំ!!ពួកគាត់នឹងដឹង!!

ខ៖ គួរណាតែឪពុកម្តាយអត់មានសូមសំនូមពរអីទេ
សូមសំណូមពរថាតែធ្វើម៉េចក៏ដោយអោយតែកូនដើរត្រង់តាមផ្លូវ
អោយតែរបស់ណាកូនគេហាមឃាត់កុំលូកលាន់ ហើយកុំបន្ទោសឪពុកម្តាយវិញ
បើកាលណាកូនដើរខុសហើយនិយាយអីហើយមិនព្រមដើរតាមគន្លងកូនធ្វើតាមអំពើស្រាច់ចិ
ត្តកូនធ្វើតាមទង្វើរបស់ខ្លួន
ទៅដេកគុកហើយឪពុកម្តាយអត់ទៅមើលទេ!!សុំទោសទៅមើលក៏មានទៅមើលដែរ
អត់អើតអត់មើលហើយអត់លឺទៀត!!

ក៖ ដោយសារនិយាយហើយហើយពូណោះ?

ខ៖  បាទ!!

ក៖ ចាំ!!

ខ៖  អញ្ចឹងបានថាមុននឹងគោស៊ី គោចូលស៊ីធ្វើរបងអោយហើយ។

ក៖  ហ្នឹងហើយ។

ខ៖  មិនមែនថាហ្វាំគោចូលស៊ីបានធ្វើរបងក្រោយអីអត់ទេ!!

ក៖ ចាំ!!

ខ៖  ធ្វើរបងឃាំងមុន។

ក៖ ចាំ!!

ខ៖  អ៊ីចឹងបានកូនអស់ហ្នឹងមិនដែលកូនមួយណាដែលថាដើរអោយវាខុសគន្លងអត់ទេ
អត់ហ៊ាន។

ក៖ ចាំ!!

ខ៖  និយាយតែមួយម៉ាត់ៗ ឪពុកថាដូចថាមីមួយនោះថា
ប៉ាញ៉ុមប្រុងទៅរកស៊ីនេះអីហ្នឹងគេហើយមើលទៅព្រោះប្រាក់ខែគេធំ!!ពុកអត់ចង់បានអញ្ចឹង
ទេ ចង់ទីមួយធ្វើម៉េចអោយតែបានបណ្ណ័សរសើរមកតែប៉ុណ្ណឹងមកបានហើយ
ឪពុកម្តាយងាប់ក៏បិតភ្នែកជិតដែរ។

ក៖ ចាំ!!

ខ៖
ញ៉ុមអ់តមានថាចង់ដើម្បីអោយកូនតបស្នងសងគុណមកចិញ្ចឹមញ៉ុមវិញមិនបាច់ទេក៏បានដែរ
ព្រោះពេលឪពុកចាស់ឡើងទៅអើរសប្បាយតែមួយចានពីរនាក់យាយក៏បានដែរ។

ក៖  ចាំមានអីទៀតទេពូ?

ខ៖  អត់ទេតែប៉ុណ្ណឹង!!

ក៖ ចាំហ្នឹងហើយ អ៊ីចឹងអរគុណច្រើនពូ។

ខ៖ បាទ!!

ក៖ សំរាប់ការរៀបរ៉ាប់ដ៏ក្បោះក្បាយពីជីវិតដែលជាទាហាន ធ្លាប់ធ្វើឆ្លបជាអ្នករត់សំបុត្រអោយគេអីវ៉ាន់អញ្ចឹងហើយធ្លាប់ធ្វើអីធ្វើអីច្រើនខ្លាំងណាស់!!អ៊ីចឹងអរគុណច្រើនសំរាប់ការសំភាសន៍មួយនេះហើយកូនចៅរបស់លោកពូគាត់នឹងបានស្តាប់ឮអំពីជីវិតរបស់លោកពូថាយ៉ាងម៉េចៗហើយកូនចៅជំនាន់ក្រោយឬក៏អ្នកដែលចង់សិក្សាក៏ពួកគាត់ក៏គាំតអាចសិក្សាពីជីវិតមនុស្សសម័យយើងឥឡូវហ្នឹងដែរពូណាស់!!ចាំអញ្ចឹងអរគុណច្រើនណាស់លោកពូ។